# ព្រះរាជក្រម

នស/រកម/០៤០៥/០០៩

## យើង

## ព្រះករុណាព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់ យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់ និងសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ ១៩៨៨ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុង អនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរគ្រឿងញៀន ខុសច្បាប់និងសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ ១៩៨៨

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់ និងសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ ១៩៨៨ ដែលធ្វើនៅទីក្រុងវីយែន នាថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៨៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពរល.០៥០៤.១៨០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា និងព្រះហស្តលេខា

ស ខេង នរោត្តម សិរីវុឌ្ឍ

លេខ ១៥៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

សូ ខាន់

313

# អនុសញ្ញា ឆ្នាំ ១៩៨៨

# របស់អង្គការសហប្រជាជាតិ

# ប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់

# និងសារធាតុដែលធ្វើអោយប៉ះពាល់ប្រព័ន្ធ

# សរសៃប្រសាទ

## អង្គការសហប្រជាជាតិ

# អនុសញ្ញា
# របស់អង្គការសហប្រជាជាតិ
# ប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់ និង សារធាតុដែលធ្វើអោយប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ

**អនុម័តដោយសន្និសីទ នាសម័យប្រជុំពេញអង្គលើកទី៦ ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ១៩៨៨**

ភាគីក្នុងអនុសញ្ញានេះ

ដោយមានការខ្វល់ខ្វាយយ៉ាងខ្លាំងចំពោះទំហំដ៏ធំធេង និង ចំពោះការកើនឡើងនៃផលិតកម្មនៃតំរូវការ និង នៃការចរាចរគ្រឿងញៀនខុសច្បាប់ និង សារធាតុប៉ះពាល់ប្រពន្ធ័សរសៃប្រសាទដែលចោទជាបញ្ហាដ៏ធ្ងន់ធ្ងរចំពោះសុខភាព និង ចំពោះសុខុមាលភាពរបស់មនុស្សជាតិហើយដែលជះឥទ្ធិពលដ៏អាក្រក់ទៅលើខឿនសេដ្ឋកិច្ច វប្បធម៌ និង នយោបាយរបស់សង្គម

ដោយមានការខ្វល់ខ្វាយយ៉ាងខ្លាំងផងដែរ ចំពោះឥទ្ធិពលបង្កិនបង្ហោចដែលកាន់តែកើនខ្លាំងក្លាឡើងៗនៃការចរាចរខុសច្បាប់គ្រឿងញៀន និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ មកលើស្រទាប់មនុស្សផ្សេងៗនៅក្នុងសង្គម ហើយពិសេសជាងនេះតាមហេតុការណ៍ ដែលថានៅកន្លែងជាច្រើនលើពិភពលោកនេះ ក្មេងៗត្រូវបានគេយកទៅធ្វើអាជីវកម្មក្នុងឋានៈជាអ្នកប្រើប្រាស់លើទីផ្សារគ្រឿងញៀន និង យកទៅប្រើប្រាស់ក្នុងគោលដៅនៃផលិតកម្ម ការចែកចាយ និង ការធ្វើពាណិជ្ជកម្មគ្រឿងញៀនខុសច្បាប់ និងសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ហើយដែលបង្កឱ្យមានគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរមិនអាចប្រមាណបាន

ដោយទទួលស្គាល់ថា ទំនាក់ទំនងរវាងការចរាចរខុសច្បាប់ និង សកម្មភាពឧក្រិដ្ឋដែលមានការរៀបចំផ្សេងៗទៀតដែលជាប់ទាក់ទងទៅនឹងបំផ្លាញគ្រឹះសេដ្ឋកិច្ចត្រឹមត្រូវតាមច្បាប់ និង គំរាមកំហែងដល់ស្ថេរភាព សន្តិសុខ និង អធិបតេយ្យភាពរបស់រដ្ឋទាំងឡាយ

ដោយទទួលស្គាល់ផងដែរថា ការចរាចរខុសច្បាប់គឺជាសកម្មភាពឧក្រិដ្ឋអន្តរជាតិ ហើយការលុបបំបាត់នូវអំពើនេះ ទាមទារអោយមានការយកចិត្តទុកដាក់ជាបន្ទាន់ និង កំរិតអាទិភាពដ៏ខ្ពស់បំផុត

ដោយដឹងថាការចរាចរខុសច្បាប់ជាប្រភពទទួលបានកំរៃហិរញ្ញវត្ថុ និង ភោគទ្រព្យដ៏ធំធេងដែលទុកលទ្ធភាពអោយមានការជ្រៀតចូលនូវអង្គការឧក្រិដ្ឋឆ្លងដែន ហើយធ្វើឱ្យចទាសម្ព័ន្ធរដ្ឋាភិបាល ធ្វើឱ្យសកម្មភាពខាងពាណិជ្ជកម្ម និងខាងហិរញ្ញវត្ថុ ត្រឹមត្រូវតាមច្បាប់ ព្រមទាំងសង្គមទាំងមូលកករល្អក់ និងពុករលួយនៅគ្រប់កំរិតមិនថានៅកំរិតណាឡើយ

ដោយបានតាំងចិត្តថាត្រូវតែធ្វើអោយជនដែលប្រព្រឹត្តអំពើចរាចរខុសច្បាប់អស់លទ្ធភាពនឹងទទួលបានផលប្រយោជន៍ពីសកម្មភាពឧក្រិដ្ឋរបស់ពួកគេជាបន្តទៅទៀត ហើយព្រមជាមួយគ្នានោះដែរលុបបំបាត់ចោលនូវមូលហេតុចំបងៗដែលលើកទឹកចិត្តដល់ពួកគេក្នុងការប្រព្រឹត្តបែបនោះ

ដោយមានឆន្ទៈចង់លុបបំបាត់នូវមូលហេតុផ្សេងៗ ដែលជាឫសគល់នៃបញ្ហាប្រើបំពានគ្រឿងញៀន និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ជាអាទិ៍ លុបបំបាត់តំរូវការគ្រឿងញៀនខុសច្បាប់និងសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ព្រមទាំងកំរៃដ៏មហាសាលដែលបានមកពីការ ចរាចរខុសច្បាប់

ដោយពិចារណាឃើញថាចាំបាច់ត្រូវតែមានវិធានការត្រួតពិនិត្យសារធាតុមួយចំនួន មានរួមទាំងសមាសធាតុផ្សំគ្រឿងញៀន ផលិតផលគីមី និង អង្គធាតុរំលាយដែលបានត្រូវយកទៅប្រើប្រាស់នៅក្នុងការធ្វើគ្រឿងញៀន និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ហើយការដែលមានសល់ទំនេរស្រាប់ៗនូវសមាសធាតុផ្សំគ្រឿងញៀន ផលិតផលគីមី និង អង្គធាតុរំលាយទាំងនោះបាននាំអោយមានការកើនឡើងនូវការធ្វើគ្រឿងញៀន និងសារធាតុអស់នោះដោយលួចលាក់

ដោយបានតាំងចិត្តថា ត្រូវតែកែលំអកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការបង្ក្រាបការចរាចរខុសច្បាប់តាមផ្លូវសមុទ្រ

ដោយទទួលស្គាល់ថា ការលុបបំបាត់ការចរាចរខុសច្បាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវរួមគ្រប់រដ្ឋទាំងអស់ និងដោយទទួលស្គាល់ថាចាំបាច់ត្រូវតែមានការសហការគ្នាក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអន្តរជាតិចំពោះគោលដៅនេះ

ដោយទទួលស្គាល់ពីសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិក្នុងវិស័យត្រួតពិនិត្យគ្រឿងញៀន និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង ដោយមានបំណងប្រាថ្នាចង់ឱ្យអង្គការអន្តរជាតិនានា ដែលមាន

សមត្ថកិច្ចក្នុងវិស័យត្រួតពិនិត្យ ពីបញ្ហានោះគួរតែមានសកម្មភាពរបស់ខ្លួននៅក្នុងរង្វង់ក្របខ័ណ្ឌរបស់អង្គការសហប្រជាជាតិនេះ

ដោយសុំអះអាងសាជាថ្មីម្តងទៀតនូវការគាំទ្រ ចំពោះគោលការណ៍ណែនាំក្នុងសន្ធិសញ្ញានានាដែលកំពុងមានជាធរមានទាក់ទងនឹងគ្រឿងញៀន និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង ចំពោះប្រពន្ធ័ត្រួតពិនិត្យដែលបានបង្កើតឡើងដោយសន្ធិសញ្ញាទាំងអស់នោះ

ដោយទទួលស្គាល់ថា ចាំបាច់ត្រូវតែពង្រឹង និង បំពេញបន្ថែមលើវិធានការដែលមាននៅក្នុងអនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ ១៩៦១ ក្នុងអនុសញ្ញាទោលនេះដូចដែលបានធ្វើវិសោធនកម្មដោយពិធីសារឆ្នាំ១៩៧២ ដែលនិយាយពីការធ្វើវិសោធនកម្មអនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ១៩៦១ និងនៅក្នុងអនុសញ្ញាឆ្នាំ ១៩៧១ ស្តីពីសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ក្នុងគោលបំណងកាត់បន្ថយទំហំ និង វិសាលភាព នៃ ការចរាចរខុសច្បាប់ ព្រមទាំងផលវិបាកដ៏ធ្ងន់ធ្ងរនៃការចរាចរខុសច្បាប់នេះ

ដោយទទួលស្គាល់ដែរថា ចាំបាច់ត្រូវតែពង្រឹង និង បង្កើនមធ្យោបាយគតិយុត្តិដ៏មានប្រសិទ្ធភាពសំរាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងរឿងព្រហ្មទណ្ឌ ដើម្បីបង្ក្រាបសកម្មភាពនៃការធ្វើចរាចរខុសច្បាប់ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ

ដោយមានបំណងធ្វើអោយមានអនុសញ្ញាអន្តរជាតិមួយ មានលក្ខណៈទូលំទូលាយ មានប្រសិទ្ធភាព និង មានលក្ខណៈប្រតិបត្តិការ ជាពិសេសសំដៅប្រយុទ្ធប្រឆាំងនឹងការចរាចរខុសច្បាប់ ហើយដែលយកចិត្តទុកដាក់ ពីទិដ្ឋភាពផ្សេងៗនៃបញ្ហាទាំងមូល ជាពិសេសចំពោះទិដ្ឋភាពទាំងឡាយណាដែលពុំទាន់មានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិកន្លងមកក្នុងវិស័យគ្រឿងញៀន និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ

បានព្រមព្រៀងគ្នាដូចតទៅ :

## មាត្រា១ : និយមន័យ

និយមន័យតទៅនេះ ត្រូវអនុវត្តបានចំពោះបទបញ្ញត្តិទាំងអស់នៃអនុសញ្ញានេះ លើកលែងតែមានកំណត់សំគាល់ណាប្រាកដប្រជា ដែលមានប្រាប់ន័យផ្សេងពីនេះ រឺ លើកលែងតែបរិបទតម្រូវអោយមានន័យផ្សេងពីនេះទៀត :

ក) ពាក្យ "ក្រុមប្រឹក្សា" មានន័យថាក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិដែលបង្កើតឡើងដោយអនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ ១៩៦១ ហើយដែលអនុសញ្ញានេះត្រូវបានធ្វើវិសោធនកម្មដោយពិធីសារឆ្នាំ ១៩៧២ដែលនិយាយពីការធ្វើវិសោធនកម្មអនុសញ្ញាទោល ស្តីពីគ្រឿងញៀនឆ្នាំ ១៩៦១

ខ) ពាក្យ "រុក្ខជាតិ កញ្ឆា" មានន័យថារាល់រុក្ខជាតិទាំងឡាយណាដែលនៅក្នុងប្រភេទកញ្ឆា

គ) ពាក្យ "Cocaïer" "ដើមកូកា" មានន័យថារាល់ចុល្លព្រឹក្សាប្រភេទជា អេរីត្រូស៊ីឡុន

ឃ) ពាក្យ " ឈ្មួញដឹកជញ្ជូន "មានន័យថាជនទាំងឡាយណា រឺ អង្គភាពសាធារណៈ ឯកជនរឺប្រភេទផ្សេងៗទៀតដែលរ៉ាប់រងការដឹកជញ្ជូនមនុស្ស ទ្រព្យ រឺ ត្បីយោរដោយបង់ថ្លៃ

ង) ពាក្យ " គណៈកម្មការ " មានន័យថា គណៈកម្មការគ្រឿងញៀននៃក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គមកិច្ចរបស់អង្គការសហប្រជាជាតិ

ច) ពាក្យ " ការរឹបអូស " មានន័យថាការដកហូតសិទ្ធិកាន់កាប់ជាអចិន្ត្រៃយ៍នូវទ្រព្យរបស់ទៅតាមសេចក្តីសំរេចរបស់តុលាការ រឺ របស់អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត

ឆ) ពាក្យ "ការប្រគល់ដោយមានការឃ្លាំមើល" មានន័យថាវិធីដែលគេទុកឱ្យគ្រឿងញៀន រឺ សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ សារធាតុដូចមានចុះបញ្ជីក្នុងតារាងទី ១ រឺ ក្នុងតារាងទី ២ ដែលជា ឧបសម្ព័ន្ធនៃអនុសញ្ញានេះ រឺ សារធាតុជំនួសសារធាតុទាំងនេះដែលជារបស់ធ្វើខុសច្បាប់ រឺ ជាប់សង្ស័យជារបស់ធ្វើខុសច្បាប់ ឆ្លងកាត់ចូលមកក្នុងទឹកដីនៃប្រទេសមួយ រឺ ច្រើនដោយមានការដឹងឮ និង ការតាមដានត្រួតពិនិត្យ ពីអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទាំងនោះ ក្នុងបំណងរកអត្តសញ្ញាណជនដែលជាប់សង្ស័យក្នុងការប្រព្រឹត្តបទល្មើស' ដូចមានចែងស្របទៅតាមកថាខ័ណ្ឌទី ១ មាត្រា ៣ នៃអនុសញ្ញា

ជ) ពាក្យ " អនុសញ្ញាឆ្នាំ១៩៦១ " មានន័យថា អនុសញ្ញាទោល ស្តីពីគ្រឿងញៀនឆ្នាំ ១៩៦១

ឈ) ពាក្យ "អនុសញ្ញាឆ្នាំ១៩៦១ ដែលបានធ្វើវិសោធនកម្ម " មានន័យថាអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ដែលបានកែប្រែដោយពិធីសារឆ្នាំ ១៩៧២ ដែលនិយាយពីការធ្វើវិសោធនកម្ម អនុសញ្ញាទោល ស្តីពីគ្រឿងញៀនឆ្នាំ១៩៦១

ញ) ពាក្យ" អនុសញ្ញាឆ្នាំ ១៩៧១ " មានន័យថាអនុសញ្ញាឆ្នាំ១៩៧១ស្តីពីសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ

ង) ពាក្យ " ក្រុមប្រឹក្សា " មានន័យថាក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គមកិច្ចនៃអង្គការសហប្រជាជាតិ

ច) ពាក្យ " ការផ្អាក " រឺ "ការឃាត់ទុក" មានន័យថាការហាមជាបណ្តោះអាសន្នមិនឱ្យមានការផ្ទេរ ការប្តូរ ការទុកដាក់ រឺ ការធ្វើចលនាទ្រព្យរបស់ រឺក៏ ការទទួលបន្ទុកជាបណ្តោះអាសន្នក្នុងការរក្សា រឺ ការត្រួតពិនិត្យទ្រព្យរបស់ទាំងនោះតាមសេចក្តីសំរេចរបស់តុលាការ រឺ អាជ្ញាធរមានសមត្ថកិច្ចផ្សេងមួយទៀត

ឆ) ពាក្យ " ការចរាចរខុសច្បាប់ " មានន័យថា បទល្មើសដូចមានចែងនៅក្នុងមាត្រា៣ កថាខ័ណ្ឌ ១ និង ២ នៃអនុសញ្ញានេះ

ជ) ពាក្យ " គ្រឿងញៀន " មានន័យថាសារធាតុទាំងឡាយណាមិនថាមានដើមកំណើតពីធម្មជាតិ រឺ ពីសំយោគទេ ដែលមាននៅក្នុងតារាងទី១ និង តារាងទី២ នៃអនុសញ្ញាទោលឆ្នាំ ១៩៦១ និងអនុសញ្ញាឆ្នាំ ១៩៦១ដែលបានធ្វើវិសោធនកម្ម

ឈ) ពាក្យ " ដើមអាភៀន " មានន័យថារុក្ខជាតិដែលនៅក្នុងប្រភេទប៉ាប៉ាវែរសុំនីហ្វេរុមអិល Papaver somniferum L.

ញ) ពាក្យ " ផលិតផល " មានន័យថាទ្រព្យរបស់ទាំងអស់ទោះជាមានដើម កំណើតបណ្តាលដោយផ្ទាល់ រឺ ដោយប្រយោលមកពីការប្រព្រឹត្តបទល្មើសណាមួយដូចមានចែងក្នុងកថាខ័ណ្ឌ១ មាត្រា ៣ រឺទ្រព្យរបស់ដែលបានមកដោយផ្ទាល់ រឺ ដោយប្រយោលដោយប្រព្រឹត្តបទល្មើសនោះ

ដ) ពាក្យ "ទ្រព្យ " មានន័យថា ទ្រព្យ ដែលមានគ្រប់ប្រភេទ ទោះជារូបទ្រព្យក្តី រឺ អរូបទ្រព្យក្តី ជាសង្ហារឹម រឺ អសង្ហារឹមក្តី ផុសនីយក្តី ព្រមទាំង រឺ អផុសនីយក្តី និង លិខិតគតិយុត្ត រឺ ឯកសារ បញ្ជាក់ពីកម្មសិទ្ធិនៃទ្រព្យទាំងនោះ រឺ ពីសិទ្ធិពាក់ព័ន្ធនឹងទ្រព្យទាំងនោះ

ឋ) ពាក្យ " សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ " មានន័យថារាល់សារធាតុទាំងឡាយណាទោះមានដើមកំណើតមកពីធម្មជាតិ រឺ មកពីសំយោគក្តី រឺក៏ផលិផលធម្មជាតិនៃតារាងទី១ តារាងទី២ តារាងទី៣ រឺ តារាងទី៤ នៃអនុសញ្ញាឆ្នាំ១៩៧១ស្តីពីសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ

ឌ) ពាក្យ " អគ្គលេខាធិការ " មានន័យថា អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ

ឍ) ពាក្យ " តារាងទី១ " និង " តារាងទី២ " មានន័យថាបញ្ជីសារជាតិជាឧបសម្ព័ន្ធនៃអនុសញ្ញានេះ ដែលត្រូវបានកែប្រែ ពីពេលមួយទៅពេលមួយទៀត ស្របតាមមាត្រា១២

ណ) ពាក្យ "រដ្ឋឆ្លងកាត់" មានន័យថារដ្ឋណាមួយ ដែលនៅលើទឹកដីរបស់រដ្ឋនោះ សារធាតុគ្រឿងញៀនខុសច្បាប់ សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង សារធាតុដែលមានចុះបញ្ជីក្នុង

តារាងទី១ និង តារាងទី២ ត្រូវបានផ្លាស់ទី ហើយរដ្ឋឆ្លងកាត់នោះមិនមែនជាចំនុចដើមកំណើត និង មិនមែនជាចំនុចកន្លែងទទួលចុងក្រោយនៃសារធាតុទាំងនោះទេ ។

## មាត្រា២ : វិសាលភាពនៃអនុសញ្ញា

១. គោលបំណងនៃអនុសញ្ញានេះ គឺធ្វើយ៉ាងណាដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការរវាងភាគីផ្សេងៗឱ្យមានប្រសិទ្ធភាពជាងមុន អាចប្រឆាំងទល់នឹងទ្រង់ទ្រាយផ្សេងៗនៃការចរាចរគ្រឿងញៀនខុសច្បាប់ និងសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទដែលមានទំហំអន្តរជាតិ ។ ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យស្របជាចំខាតតាមអនុសញ្ញា ភាគីត្រូវប្រកាន់យកវិធានការចាំបាច់ រួមមានទាំងវិធានការច្បាប់ និង វិធានការរដ្ឋបាល ដោយអោយវិធានការទាំងនោះចុះសំរុងនឹងបទបញ្ញត្តិគោលនៃប្រពន្ធ័ច្បាប់ក្នុងប្រទេសនីមួយៗ ។

២. ភាគីទាំងឡាយត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដូចមានចែងនៅក្នុងអនុសញ្ញានេះ អោយចុះសំរុងជាមួយនឹងគោលការណ៍សមភាព ខាងអធិបតេយ្យ និង គោលការណ៍បូរណភាពដែនដីរបស់រដ្ឋ និង ព្រមទាំងជាមួយគោលការណ៍ មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃ ។

៣. រាល់ភាគីទាំងអស់ មិនត្រូវអនុវត្តនៅលើទឹកដីរបស់ភាគីម្ខាងទៀត នូវដែនសមត្ថកិច្ច និងការបង្កើតមុខងារទាំងឡាយ ដែលជាមុខងារជាចំមុខរបស់អាជ្ញាធរនៃភាគីម្ខាងទៀត តាមច្បាប់ក្នុងប្រទេសរបស់ខ្លួនបានឡើយ។

## មាត្រា៣ : បទល្មើស និង ទណ្ឌកម្ម

១. ភាគីនីមួយៗត្រូវអនុម័តនូវវិធានផ្សេងដែលមានលក្ខណៈចាំបាច់ ដើម្បីកំណត់អោយលក្ខណៈបទល្មើសព្រហ្មទណ្ឌទាំងឡាយ អនុលោមតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន ពេលដែលអំពើបានប្រព្រឹត្តដោយចេតនា :

ក) i) ក្នុងការផលិត ការធ្វើនិស្សារណកម្ម ការផ្សំ ការផ្គត់ផ្គង់ទីផ្សារ ការផ្គត់ផ្គង់សំរាប់លក់ ការចែកចាយ ការលក់ ការប្រគល់ទោះជាក្នុងល័ក្ខខ័ណ្ឌណាក៏ដោយ ក្នុងរបរជើងសារ របស់ផ្ញើ របស់ផ្ញើដោយឆ្លងកាត់ ការដឹកជញ្ជូន ការនាំចូល រឺ ការនាំចេញគ្រឿងញៀន និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទគ្រប់ប្រភេទ ល្មើសនឹងបទបញ្ញត្តិនៃអនុសញ្ញា ឆ្នាំ១៩៦១ អនុសញ្ញាឆ្នាំ ១៩៦១ ដែលត្រូវបានកែប្រែ រឺ នៃអនុសញ្ញាឆ្នាំ ១៩៧១ បានទេ

ii) ក្នុងការដាំដើមអាភៀន ដើមកូកា រឺ រុក្ខជាតិកញ្ឆា ក្នុងគោលបំណងធ្វើការផលិតគ្រឿងញៀន ល្មើសនឹងបទបញ្ញត្តិនៃអនុសញ្ញាឆ្នាំ១៩៦១ និង នៃអនុសញ្ញាឆ្នាំ ១៩៦១ ដែលបានកែប្រែ

iii) ក្នុងការរក្សាទុក រឺ ការទិញគ្រឿងញៀន រឺសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទគ្រប់ប្រភេទ ក្នុងគោលបំណងធ្វើសកម្មភាពណាមួយដូចបានរៀបរាប់ក្នុងវគ្គរង i ខាងលើ

iv) ក្នុងការធ្វើ ការដឹកជញ្ជូន រឺ ការចែកចាយនូវបរិក្ខារ សំភារៈ រឺ កំនូវសារធាតុដូចមាន ចុះបញ្ជីក្នុងតារាងទី ១ និង តារាងទី២ ហើយជនដែលប្រព្រឹត្តនោះដឹងថា ត្រូវយកទៅប្រើប្រាស់ក្នុង រឺ សំរាប់ការ ដាំដុះ ការផលិត ការធ្វើខុសច្បាប់គ្រឿងញៀន រឺ សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ

v) ក្នុងការរៀបចំ ការដឹកនាំ រឺ ការធ្វើហិរញ្ញប្បទាន ជួយបទល្មើសណាមួយ ដូចដែលបានរៀបរាប់នៅក្នុងវគ្គរង i វគ្គរង ii វគ្គរង iii រឺ វគ្គរង iv ខាងលើ

ខ) i) នៅក្នុងការប្តូរ រឺ ការផ្ទេរទ្រព្យដែលជនប្រព្រឹត្តនោះដឹងថា ទ្រព្យទាំងអស់នោះ បានមកពីបទល្មើសណាមួយដូចមានចែងស្របតាមវគ្គ (ក) នៃកថាខ័ណ្ឌនេះ រឺក៏បានមកពីការចូលរួមប្រព្រឹត្តបទល្មើសនោះក្នុងគោលបំណងដើម្បីបិទបាំង រឺ ក្លែងបន្លំ ដើមកំណើតខុសច្បាប់នៃទ្រព្យទាំងនោះ រឺ ដើម្បីផ្តល់ជំនួយដល់ជនដែលពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើសនោះឱ្យគេចផុតពីផលវិបាកគតិយុត្តនៃអំពើរបស់ខ្លួន

ii) ក្នុងការបិទបាំង រឺ ក្លែងបន្លំពីធម្មជាតិ ពីដើមកំណើត ពីទីកន្លែង ពីការទុកដាក់ ពីចលនា រឺ ពីកម្មសិទ្ធិពិតប្រាកដនៃទ្រព្យរបស់ រឺក៏ ពីសិទ្ធិពាក់ព័ន្ធនឹងទ្រព្យដែលជនល្មើសដឹងថា ទ្រព្យទាំងនោះ បានមកពីបទល្មើសណាមួយដូចមានចែងក្នុងវគ្គ (ក) នៃកថាខ័ណ្ឌនេះ រឺ ក៏បានមកពីការចូលរួមប្រព្រឹត្តបទល្មើសទាំងនោះណាមួយ

គ) លើកលែងតែមានគោលការណ៍ច្បាប់រដ្ឋធម្មនុញ្ញរបស់ភាគី និងគោលការណ៍ជាសារវន្តនៃប្រព័ន្ធគតិយុត្តរបស់ខ្លួន

i) ការទទួល ការរក្សារទុក រឺ ការប្រើប្រាស់ទ្រព្យ ការទទួលស្គាល់ ដែលទ្រព្យទាំងនោះបានមកពីបទល្មើសណាមួយដូចមានចែងក្នុងវគ្គ (ក) នៃកថាខ័ណ្ឌនេះ រឺ បានមកពីការចូលរួមក្នុងការប្រព្រឹត្តបទល្មើសណាមួយនោះ

ii) ក្នុងការរក្សាទុកបរិក្ខារ សំភារៈ រឺ សារធាតុដូចមានចុះបញ្ជីនៅក្នុងតារាងទី១ រឺតារាងទី២ ដែលជនរក្សាទុកបរិក្ខារ សំភារៈ រឺ សារធាតុទាំងនោះ ដឹងថា របស់ទាំងនោះបានយកទៅ

ប្រើប្រាស់ ឬ ត្រូវយកទៅប្រើប្រាស់ក្នុង ឬ សំរាប់ការដាំដុះ សំរាប់ការផលិត ឬសំរាប់ការធ្វើគ្រឿងញៀនខុសច្បាប់ ឬ សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ

iii) ក្នុងការញុះញង់ ឬ បបួលអ្នកដទៃជាសាធារណៈ ទោះជាតាមមធ្យោបាយណាក៏ដោយអោយប្រព្រឹត្តបទល្មើសណាមួយដូចមានចែង អនុលោមតាមមាត្រានេះ ឬក៏ឱ្យប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ឬ សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ

iv) ក្នុងការចូលរួមប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងអនុលោមតាមមាត្រានេះ ឬក៏ក្នុងការរួមគ្នា ការព្រមព្រៀងគ្នា ការប៉ុនប៉ង ឬ ការផ្សំគំនិត ដោយផ្តល់ការជួយទំនុកបំរុង ការផ្តល់ជំនួយ ឬ ការជួយណែនាំឱ្យប្រព្រឹត្តបទល្មើស ។

២. លើកលែងតែមានគោលការណ៍ច្បាប់រដ្ឋធម្មនុញ្ញរបស់ភាគី និង គោលការណ៍ជាសារវន្តនៃប្រព័ន្ធគតិយុត្តរបស់ខ្លួន ភាគីនីមួយៗត្រូវអនុម័តយកវិធានការចាំបាច់ផ្សេងៗ ដើម្បីកំណត់អោយលក្ខណៈបទល្មើសព្រហ្មទណ្ឌ ដោយអនុលោមតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន កាលបើមានអំពើប្រព្រឹត្តដោយចេតនាក្នុងការរក្សាទុក និង ក្នុងការទិញគ្រឿងញៀន និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង ក្នុងការដាំដុះគ្រឿងញៀន សំរាប់ប្រើប្រាស់ផ្ទាល់ខ្លួនដោយរំលោភលើបទបញ្ញត្តិអនុសញ្ញាឆ្នាំ១៩៦១ អនុសញ្ញាឆ្នាំ១៩៦១ ដែលបានកែប្រែ ឬក៏ អនុសញ្ញាឆ្នាំ១៩៧១ ។

៣. ការដឹង ចេតនា ឬ មូលហេតុចាំបាច់ផ្សេងៗ ក្នុងន័យជាធាតុផ្សំនៃបទល្មើសណាមួយ ដូចមានចែងនៅក្នុងកថាខ័ណ្ឌ១នៃមាត្រានេះ អាចទាញបានពីស្ថានភាពទាក់ទងនឹងហេតុការណ៍សត្យានុម័តផ្សេងៗ ។

៤. ក) ភាគីនីមួយៗត្រូវធ្វើអោយបទល្មើសដូចមានចែងអនុលោមតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ អាចធ្វើទោសទណ្ឌកម្មបានទៅតាមភាពធ្ងន់ធ្ងរនៃបទល្មើស ដូចជាការដាក់ពន្ធនាគារ ឬ ទោសដកហូតសេរីភាព ការផាកពិន័យ និងការរឹបអូសផ្សេងទៀតជាដើម

ខ) ភាគីអាចគ្រោងទុកនូវវិធានការបន្ថែមផ្សេងៗពីលើការផ្តន្ទាទោស ឬ ពីលើទណ្ឌកម្ម ព្រហ្មទណ្ឌដែលបានកាត់ ចំពោះបទល្មើសដូចមានចែងស្របតាមកថាខ័ណ្ឌ១នៃមាត្រានោះ ដោយអោយជនល្មើសនៃបទល្មើសទទួលយកវិធានការព្យាបាល អប់រំក្រោយពីការជាសះស្បើយ វិធានការស្តារនីតិសម្បទាឡើងវិញ ឬ វិធានការសមាហរ័ណកម្មទៅក្នុងសង្គមវិញ

គ) ទោះជាមានបទបញ្ញត្តិនៅក្នុងវគ្គពីមុន១ហើយក្តី នៅក្នុងករណីសមស្រប ចំពោះបទល្មើសកំរិតតូចតាច ភាគីអាចគ្រោងទុកជាអាទិ៍ វិធានការផ្សេង១ជំនួសការផ្តន្ទាទោស រឺទណ្ឌកម្មព្រហ្មទណ្ឌ ដូចជា វិធានការអប់រំ ធ្វើនីតិសម្បទាឡើងវិញ រឺវិធានការសមាហរណកម្មទៅក្នុងសង្គមវិញ ក៏ដូចជាវិធានការព្យាបាល និង ក្រោយពីជាសះស្បើយ កាលបើជនល្មើសនៃបទល្មើសជាជនញៀនគ្រឿងញៀន

ឃ) ភាគីអាចគ្រោងទុកវិធានការផ្សេង១ មានព្យាបាល អប់រំក្រោយពីជាសះស្បើយ ការស្តារនីតិសម្បទាឡើងវិញ រឺធ្វើសមាហរណកម្មទៅក្នុងសង្គមវិញ របស់ជនល្មើសនៃបទល្មើសជាជំនួសទណ្ឌកម្ម រឺ ទោសដែលបានកាត់ រឺមួយបន្ថែមពីលើទណ្ឌកម្ម រឺ ទោសទាំងនោះ ចំពោះបទល្មើសដូចមានចែងស្របតាមបទបញ្ញត្តិកថាខ័ណ្ឌ ២ នៃមាត្រានេះ ។

៥. ភាគីទាំងឡាយ ត្រូវធានាយ៉ាងណាឱ្យតុលាការរបស់ខ្លួន និង អាជ្ញាធរមានសមត្ថកិច្ចដទៃទៀត អាចយកចិត្តទុកដាក់ពីស្ថានភាពទាក់ទងនឹងហេតុការណ៍ផ្សេង១ សំរាប់កំណត់អោយលក្ខណៈពិសេសនៃភាពធ្ងន់ធ្ងរចំពោះបទល្មើសដូចមានចែងស្របតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ដូចជា :

ក) ការចូលរួមប្រព្រឹត្តបទល្មើស នៃអង្គការជនទុច្ចរិត ដែលជនល្មើសនៃបទល្មើសឋិតនៅក្នុងនោះ

ខ) ការចូលរួមរបស់ជនល្មើសក្នុងសកម្មភាពនៃបទឧក្រិដ្ឋដទៃទៀត ដែលបានរៀបចំឡើងជាលក្ខណៈអន្តរជាតិ

គ) ការចូលរួមរបស់ជនល្មើសក្នុងសកម្មភាពខុសច្បាប់ដទៃទៀត ដែលសំរួលដោយការប្រព្រឹត្តបទល្មើស

ឃ) ការប្រើវិធីហឹង្សា រឺ អាវុធពីសំណាក់ជនល្មើស

ង) ដោយមកពីជនល្មើសទទួលបន្ទុកការងាររដ្ឋ ហើយបទល្មើសនោះជាប់ទាក់ទងនឹង ការងាររដ្ឋដែលខ្លួនទទួលខុសត្រូវនោះ

ច) ការធ្វើឱ្យរងគ្រោះដល់អនីតិជន រឺ ការប្រើអនីតិជន

ឆ) ដោយមកពីបទល្មើសដែលបានប្រព្រឹត្តស្ថិត ក្នុងគ្រឹះស្ថានពន្ធនាគារ គ្រឹះស្ថានអប់រំ មជ្ឈមណ្ឌលផ្តល់សេវាកម្មសង្គម រឺ នៅម្តុំជិត១កន្លែងទាំងនោះ រឺក៏នៅកន្លែងដទៃទៀត ដែលសិស្សសាលា និង និស្សិត ប្រព្រឹត្តខ្លួនក្នុង សកម្មភាពអប់រំ សកម្មភាពកីឡា រឺសកម្មភាពសង្គមផ្សេង១

ជ) ក្នុងករណីច្បាប់ក្នុងប្រទេសរបស់ភាគីអនុញ្ញាតចំពោះការដាក់ទណ្ឌកម្មផ្សេង១ ពីមុន១មកជាពិសេស ចំពោះបទល្មើសដូច១គ្នា ដែលប្រព្រឹត្តនៅក្នុងប្រទេសខ្លួន រឺក៏នៅឯបរទេស ។

៦. ភាគីនីមួយៗ ត្រូវខិតខំធ្វើយ៉ាងណាឱ្យអំណាចតុលាការឆន្ទានុសិទ្ធដែលបានប្រគល់ឱ្យដោយច្បាប់ក្នុងប្រទេសរបស់ខ្លួនហើយដែលទាក់ទងទៅនឹងការចោទប្រកាន់ខាងតុលាការ លើបុគ្គលទាំងឡាយ ចំពោះបទល្មើសដូចមានចែងស្របតាមមាត្រានេះត្រូវបានអនុវត្ត ដោយបង្កើនគិតប្រសិទ្ធភាព វិធានការរាវរក និង វិធានការបង្ក្រាបឱ្យបានជាអតិបរិមា ដល់អ្វីដែលជាបទល្មើសដូចមានមកនោះ រាប់ទាំងភាពចាំបាច់ក្នុងការរារាំងឱ្យបានសមស្របទាក់ទងនឹងការប្រព្រឹត្តល្មើសរបស់បុគ្គលនោះ ។

៧. ភាគីទាំងឡាយត្រូវធានាអោយ តុលាការរបស់ខ្លួន រឺ អាជ្ញាធរមានសមត្ថកិច្ចដទៃទៀតយកចិត្តទុកដាក់ពិចារណាពីភាពធ្ងន់ធ្ងរនៃបទល្មើសដូចបានរៀបរាប់នៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ និង យកចិត្តទុកដាក់ពិចារណាពីស្ថានភាពទាំងឡាយដូចមានចែងនៅក្នុងកថាខ័ណ្ឌ ៥ នៃមាត្រានេះ នៅពេលដែល ភាគីពិនិត្យពីលទ្ធភាព ក្នុងការដោះលែងមុនកាលកំណត់ រឺដោះលែងដោយមានល័ក្ខខ័ណ្ឌ បុគ្គលដែលគេបានស្គាល់ថា ជាពិរុទ្ធជននៃបទល្មើសទាំងនោះ ។

៨. ភាគីនីមួយៗត្រូវបញ្ជាក់ ក្នុងក្របខ័ណ្ឌច្បាប់ក្នុងប្រទេសរបស់ខ្លួន ពីរយៈពេលនៃអាជ្ញាយុកាលដែលត្រូវបន្តកាលបើមានហើយដែលនៅក្នុងរយៈពេលនោះ ការចោទប្រកាន់នានាអាចមានលើចំនុចសំខាន់នៃបទល្មើសណាមួយ ដូចមានចែងស្របតាមកថាខ័ណ្ឌ១នៃមាត្រានេះ ហើយរយៈពេលនេះនឹងកាន់តែវែងជាងមុន កាលបើជនល្មើសដែលត្រូវបានចោទប្រកាន់បានគេចវេសពីរដ្ឋបាលតុលាការ ។

៩. ភាគីនីមួយៗត្រូវចាត់វិធានការសមស្រប ដោយអនុលោមទៅតាមប្រព័ន្ធគតិយុត្តរបស់ខ្លួន ដើម្បីឱ្យជនដែលជាប់ចោទ រឺ ដែលជាពិរុទ្ធជននៃបទល្មើសមួយ ដូចមានចែងស្របតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ដែលជននោះមានវត្តមាននៅក្នុងទឹកដីរបស់ភាគីនោះចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌដែលចាំបាច់។

១០. ក្នុងគោលបំណងនៃកិច្ចសហប្រតិបត្តិការរវាងភាគីនៅក្នុងអនុសញ្ញានេះ និង ជាពិសេស កិច្ចសហប្រតិបត្តិការស្របតាមមាត្រា ៥ មាត្រា៦ មាត្រា៧ និង មាត្រា ៩ ដោយគ្មានឡំអៀងដល់ក្របខ័ណ្ឌច្បាប់រដ្ឋធម្មនុញ្ញ និង ដល់ច្បាប់គោលរបស់ភាគី បទល្មើសទាំងឡាយដូចមានចែងស្របតាមមាត្រានេះមិនត្រូវចាត់ទុកថាជាបទល្មើសខាងសារពើពន្ធ រឺ ជា បទល្មើសខាងនយោបាយហើយក៏មិនត្រូវចាត់ទុកថាជាបទល្មើស ដែលមានមូលហេតុពាក់ព័ន្ធខាងនយោបាយនោះទេ ។

១១. គ្មានបទបញ្ញត្តិណាមួយនៅក្នុងមាត្រានេះ ប៉ះពាល់ដល់គោលការណ៍ ដែលតាមរយៈគោលការណ៍នោះការកំណត់បទល្មើស មានចែងប្រាប់ស្រាប់ក្នុងនោះ និង មធ្យោបាយគតិយុត្តខាងការការពារខ្លួនដែលពាក់ព័ន្ធនឹងគោលការណ៍នោះ ទាក់ទងតែទៅនឹងច្បាប់ក្នុងប្រទេសនៃភាគីនីមួយៗនោះហើយដែលតាម

រយៈគោលការណ៍នោះ បទល្មើសដូចបានពោលទាំងឡាយនោះត្រូវបានធ្វើការចោទប្រកាន់ និង ដាក់ទណ្ឌកម្មស្របតាមច្បាប់ដូចបានពោលមកហើយនោះ ។

## មាត្រា៤ : យុត្តាធិការ

១. ភាគីនីមួយៗ :

ក) ត្រូវអនុម័តយកវិធានការចាំបាច់ផ្សេងៗ ដើម្បីបង្កើតសមត្ថកិច្ចរបស់ខ្លួន ទៅតាមបទល្មើសដែលខ្លួនបានលើកស្របតាមកថាខ័ណ្ឌ ១ នៃមាត្រា ៣ កាលបើ :

i) បទល្មើសបានប្រព្រឹត្ត នៅក្នុងទឹកដីរបស់ខ្លួន

ii) បទល្មើសបានប្រព្រឹត្តនៅលើនាវា ដែលមានដោតទង់ជាតិរបស់ខ្លួនជាសំគាល់ រឺនៅលើយន្តហោះ ដែលមានចុះបញ្ជីស្របតាមច្បាប់នៃប្រទេសខ្លួន ក្នុងពេលដែលបទល្មើសបានប្រព្រឹត្ត

ខ) អាចអនុម័តយកវិធានការចាំបាច់ផ្សេងៗ ដើម្បីបង្កើតសមត្ថកិច្ចរបស់ខ្លួនទៅតាមបទល្មើសដែលភាគី បានចែង ស្របតាមកថាខ័ណ្ឌ១ នៃមាត្រា ៣ កាលបើ :

i) បទល្មើសត្រូវបានប្រព្រឹត្តដោយជនជាតិរបស់ខ្លួន រឺ ដោយជនណាម្នាក់ដែលស្នាក់នៅជាធម្មតានៅក្នុងទឹកដីរបស់ភាគី

ii) បទល្មើសបានប្រព្រឹត្តនៅលើនាវា ហើយដើម្បីទប់ទល់នឹងបទល្មើសនោះ ភាគីបានអនុញ្ញាតអោយមានវិធានការសមស្របតាមមាត្រា ១៧ លើកលែងតែសមត្ថកិច្ចនេះត្រូវប្រព្រឹត្តទៅបានលុះត្រាតែមានកិច្ចព្រមព្រៀង រឺកិច្ចសំរុះសំរួលដូចមានចែងក្នុងកថាខ័ណ្ឌ ៤ និង កថាខ័ណ្ឌ ៥ នៃមាត្រាដូចបានពោលនោះ

iii) បទល្មើសគឺជាបទល្មើសណាមួយក្នុងចំណោមបទល្មើសនានា ដូចមានចែងអនុលោមតាមមាត្រា ៣ កថាខ័ណ្ឌ១ ត្រង់វគ្គ (គ)(iv) ហើយដែលបានប្រព្រឹត្ត នៅក្រៅទឹកដីរបស់ភាគីក្នុងចេតនាប្រព្រឹត្តបទល្មើសណាមួយដូចមានចែងអនុលោមតាមមាត្រា ៣ កថាខ័ណ្ឌ ១ នៅក្នុងទឹកដីរបស់ភាគី ។

២. ភាគីនីមួយៗ :

(ក) ក៏ត្រូវអនុម័ត យកវិធានការចាំបាច់ផ្សេងៗ ដើម្បីបង្កើតសមត្ថកិច្ចរបស់ខ្លួនផងដែរ ទៅតាមបទល្មើសដែលភាគីខ្លួនឯងបានកំណត់ ដោយអនុលោមទៅតាមមាត្រា ៣ កថាខ័ណ្ឌ១ កាលបើជនល្មើសដែលគេចាត់ទុក ថា បានប្រព្រឹត្តបទល្មើស មានវត្តមាននៅក្នុងទឹកដីរបស់ភាគី ហើយ

ដែលភាគីនោះមិនធ្វើបត្យាប័នអោយជននោះទៅកាន់ទឹកដីរបស់គូភាគីម្ខាងទៀត ដោយមូលហេតុថា :

i) បទល្មើសបានប្រព្រឹត្តនៅក្នុងទឹកដីរបស់ភាគី រឺនៅលើនាវាដែលមានដោតទង់ជាតិរបស់ភាគីនោះជាសំគាល់ រឺនៅលើយន្តហោះដែលមានចុះបញ្ជី ស្របតាមច្បាប់របស់ប្រទេសភាគីនោះពេលដែលបទល្មើសបានប្រព្រឹត្ត រឺ

ii) បទល្មើសបានប្រព្រឹត្តឡើង ដោយជនជាតិរបស់ខ្លួន

(ខ) ក៏ត្រូវអនុម័តយកវិធានការចាំបាច់ផ្សេងៗ ដើម្បីបង្កើតសមត្ថកិច្ចរបស់ខ្លួនផងដែរ ទៅតាមបទល្មើស ដែលភាគីបានកំណត់ដោយអនុលោមតាមមាត្រា ៣ កថាខ័ណ្ឌ ១ កាលបើជនល្មើសដែលគេ ចាត់ទុកថាបានប្រព្រឹត្តបទល្មើស មានវត្តមាននៅក្នុងទឹកដីរបស់ភាគី ហើយដែលភាគីនោះមិនធ្វើបត្យាប័នជននោះ ទៅកាន់ទឹកដីរបស់គូរភាគីម្ខាងទៀត ។

៣. អនុសញ្ញានេះមិនបានលើកលែង ចំពោះការអនុវត្តសមត្ថកិច្ចខាងព្រហ្មទណ្ឌ ដែលបានបង្កើតដោយភាគីណាមួយ ស្របតាមច្បាប់ក្នុងប្រទេសរបស់ខ្លួននោះឡើយ ។

## មាត្រា ៥ :ការរឹបអូស

១. ភាគីនីមួយៗត្រូវអនុម័តយកវិធានការផ្សេងៗដែលអាចចាំបាច់សំរាប់ធ្វើការរឹបអូស :

ក) នូវផលិតផលដែលបានមកពីបទល្មើស ដូចមានចែងស្របតាមមាត្រា៣ កថាខ័ណ្ឌ១ រឺ ទ្រព្យរបស់ ដែលតំលៃរបស់វាស្មើនឹងតំលៃនៃផលិតផលដូចពោលទាំងនោះ

ខ) នូវគ្រឿងញៀន និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ សំភារៈ និង គ្រឿងបរិក្ខារ រឺឧបករណ៍ផ្សេងទៀតដែលប្រើប្រាស់ រឺដែលនឹងត្រូវបានកំណត់យកទៅប្រើប្រាស់ ទោះជាតាមរបៀបណាក៏ដោយ សំរាប់ប្រព្រឹត្តបទល្មើសដូចមានចែងស្របតាម កថាខ័ណ្ឌ១ នៃមាត្រា ៣ ។

២. ម្យ៉ាងទៀត ក្នុងគោលបំណងរឹបអូសជាយថាហេតុ ភាគីនីមួយៗត្រូវអនុម័ត យកវិធានការផ្សេងៗដែលអាចចាំបាច់ដើម្បីជួយដល់ អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនធ្វើអត្តសញ្ញាណ ធ្វើការរាវរក និងការផ្អាក រឺការឃាត់ទុក ផលិតផល ទ្រព្យ ឧបករណ៍ រឺ របស់របរផ្សេងៗទៀត ដូចមាន ចែងក្នុងកថា ខ័ណ្ឌ១នៃមាត្រានេះ ។

៣. ដើម្បីអាចអនុវត្តវិធានការដូចបានគ្រោងទុកក្នុងមាត្រានេះ ភាគីនីមួយៗ ត្រូវធ្វើអោយតុលាការរបស់ខ្លួន រឺ អាជ្ញាធរមានសមត្ថកិច្ចដទៃទៀតរបស់ខ្លួនមាននីតិសម្បទា បញ្ជាគេឱ្យផលិត រឺឃាត់ទុកឯកសារធនាគារ ហិរញ្ញវត្ថុ រឺពាណិជ្ជកម្មទាំងឡាយ ។ សំរាប់បទបញ្ញត្តិនៃកថាខ័ណ្ឌនេះ ភាគីណាក៏ដោយមិនអាចប្រកែកមិនព្រម អនុវត្តដោយសំអាងលេសថាជាការសំងាត់ របស់ធនាគារបានឡើយ ។

៤. ក) តាមសេចក្តីនៃមាត្រានេះ កាលបើមានសំណើមួយត្រូវបានស្នើឡើងពីភាគីម្ខាងដែលមានសមត្ថកិច្ចវិនិច្ឆ័យបទល្មើស ដូចមានចែងស្របតាមកថាខ័ណ្ឌ១ នៃមាត្រា ៣ ភាគីដែលទឹកដីខ្លួនមានវត្តមាន ផលិតផល ទ្រព្យ ឧបករណ៍ រឺ របស់របរផ្សេងៗទៀត ដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះត្រូវៈ

i) បញ្ជូនសំណើទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការកាត់ក្តីសំរេចរឹបអូស ហើយបើប្រសិនជាសេចក្តីសំរេចរឹបអូសនោះ ត្រូវធ្វើភាគីត្រូវចាត់អោយគេអនុវត្តសេចក្តីសំរេច នោះ រឺ

ii) បញ្ជូនទៅអោយអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីអនុវត្តទៅតាមកិរិតផ្សេងៗមានក្នុងសំណើនោះនូវសេចក្តីសំរេចរឹបអូស ពីសំណាក់ភាគីដាក់សំណើ ស្របតាមកថាខ័ណ្ឌ១នៃ មាត្រានេះនូវអ្វីដែលជា ផលិតផល ទ្រព្យ ឧបករណ៍ រឺ របស់របរផ្សេងទៀត ដូចមានចែងក្នុងកថាខ័ណ្ឌ១ ហើយដែលអីវ៉ាន់ទាំងនោះ ឋិតនៅក្នុងទឹកដីរបស់ភាគីទទួលសំណើ

ខ) កាលបើសំណើមួយត្រូវបានធ្វើឡើង តាមសេចក្តីនៃមាត្រានេះពីភាគីម្ខាងទៀត ដែលមានសមត្ថកិច្ចវិនិច្ឆ័យបទល្មើសមួយដូចមានចែងស្របតាមកថាខ័ណ្ឌ១ នៃមាត្រា ៣ ភាគីទទួលសំណើត្រូវចាត់វិធានការផ្សេងៗ ដើម្បីធ្វើអត្តសញ្ញាណ រាវរក និង ផ្អាក រឺឃាត់ទុក ផលិតផលទ្រព្យ ឧបករណ៍ រឺ របស់របរផ្សេងៗទៀត ដូចមានចែងនៅក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះក្នុងគោលបំណងធ្វើការ រឹបអូសជាយថាហេតុតាមបញ្ជា រឺ មួយពីសំណាក់ភាគីដាក់សំណើ រឺមួយបន្ទាប់ពីមានសំណើមួយដែលបានលើកឡើងពីសំណាក់ភាគីទទួលសំណើ តបតាមន័យនៃវគ្គ (ក) នៃកថាខ័ណ្ឌនេះ

គ) សេចក្តីសំរេច រឺ វិធានការផ្សេងៗដូចមានគ្រោងទុកនៅក្នុងវគ្គ ក និង ខនៃកថាខ័ណ្ឌនេះហើយដែលត្រូវបានប្រកាន់យកពីសំណាក់ភាគីទទួលសំណើ ដោយអនុលោមតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន និងទៅតាមបទបញ្ញត្តិច្បាប់ដូចបានពោលមកនោះ ព្រមទាំងដោយអនុលោមស្របតាមវិធាននៃនីតិវិធីរបស់ច្បាប់ ទាំងនោះ រឺក៏ស្របតាមសន្ធិសញ្ញា កិច្ចព្រមព្រៀង រឺកិច្ចសំរុះសំរួលទ្វេភាគី រឺពហុភាគី ដែលមានរវាងភាគី ទទួលសំណើ និង ភាគីដាក់សំណើ

ឃ) បទបញ្ញត្តិនៃកថាខ័ណ្ឌ៦ រហូតដល់កថាខ័ណ្ឌ១៩ នៃមាត្រា៧ ត្រូវយកទៅអនុវត្តបានដោយធ្វើការប្រែប្រួលជាចាំបាច់ផ្សេងៗ mutatis mutandis ។ លើសពីពត៌មាន ដូចមានចែងនៅក្នុងកថាខ័ណ្ឌ១០នៃមាត្រា៧ បណ្តឹងទាមទារដែលបានធ្វើស្របតាមមាត្រានេះ ត្រូវមានពត៌មានបន្ថែមដូចតទៅ:

i) សេចក្តីអធិប្បាយពីទ្រព្យរបស់ដែលត្រូវរឹបអូស ព្រមទាំងសេចក្តីបញ្ជាក់ពីហេតុការណ៍ផ្សេងៗដែលភាគីដាក់សំណើបានលើកយកមកអះអាង ដើម្បីជួយឱ្យភាគីទទួលសំណើធ្វើការកាត់ក្តីសំរេចរឹបអូស នៅក្នុងក្របខ័ណ្ឌច្បាប់ក្នុងប្រទេសរបស់ខ្លួន កាលបើសំណើទាក់ទងទៅនឹង វគ្គ ក , i នៃកថាខ័ណ្ឌនេះ

ii) លិខិតចំលងដែលយកជាការបាន តាមផ្លូវច្បាប់មួយច្បាប់នៃសេចក្តីសំរេចរឹបអូស ដែលផ្តល់ពីសំណាក់ភាគីដាក់សំណើ ហើយដែលនៅលើលិខិតចំលងនោះ សំណើត្រូវមានសេចក្តីបញ្ជាក់ពីហេតុការណ៍ និង ពីពត៌មានផ្សេងៗ ដែលចង្អុលប្រាប់ពីកំរិតកំណត់ដែលគេស្នើអោយអនុវត្តសេចក្តីសំរេចនោះ កាលបើសំណើទាក់ទង ទៅនឹងវគ្គ ក. ii

iii) សេចក្តីបញ្ជាក់ពីហេតុការណ៍ ដែលភាគីដាក់សំណើ លើកយកមកសំអាង និង សេចក្តីអធិប្បាយ ពីវិធានការផ្សេងៗដែលបានស្នើ កាលបើសំណើទាក់ទងទៅនឹងវគ្គ(ខ)

ង) ភាគីនីមួយៗ ត្រូវជូនដំណឹងទៅអគ្គលេខាធិការនូវអត្ថបទច្បាប់ និង បទបញ្ជារបស់ខ្លួនដែលធ្វើអោយកថាខ័ណ្ឌនេះអនុវត្តបានព្រមទាំងអត្ថបទកែប្រែ ក្រោយមកទៀតដែលមានចំពោះច្បាប់និង បទបញ្ជាទាំងនោះ

ច) បើប្រសិនជា ភាគីណាមួយ សំរេចអនុម័តយកវិធានការដូចមានចែងក្នុងវគ្គ ក និង ខ នៃកថាខ័ណ្ឌនេះបានទាល់តែមានសន្ធិសញ្ញាមួយស្តីពីប្រធានបទនោះ ភាគីនោះត្រូវជឿថា អនុសញ្ញានេះគឺជាមូលដ្ឋាននៃ សន្ធិសញ្ញាដែលមានលក្ខណៈចាំបាច់ និង គ្រប់គ្រាន់បំផុតមួយ

ឆ) ភាគីទាំងឡាយ ត្រូវខិតខំធ្វើឱ្យមានសន្ធិសញ្ញា កិច្ចព្រមព្រៀង រឺ កិច្ចសំរុះសំរួលផ្សេងៗជាទ្វេរភាគី និង ពហុភាគី ដើម្បីពង្រឹងប្រសិទ្ធភាព កិច្ចសហប្រតិបត្តិការអន្តរជាតិ តាមគោលបំណងនៃមាត្រានេះ ។

៥. ក) គ្រប់ភាគីដែលរឹបអូសផលិតផល រឺ ទ្រព្យរបស់ ដោយអនុវត្តតាមកថាខ័ណ្ឌ១ រឺ កថាខ័ណ្ឌ៤ នៃមាត្រានេះ អាចទុកដាក់របស់របរទាំងនោះ ស្របទៅតាមច្បាប់ក្នុងប្រទេស និងទៅតាមនីតិវិធីរដ្ឋបាលរបស់ខ្លួន

ខ) កាលបើ ភាគីមួយធ្វើសកម្មភាពតាមសំណើពីភាគីម្ខាងទៀត ដោយអនុវត្តតាមមាត្រានេះ ភាគីនោះអាចយកមកពិនិត្យធ្វើកិច្ចព្រមព្រៀងផ្សេងៗ ដោយគ្រោងទុកជាមុនជា ពិសេសពី :

i) ការបរិច្ចាគ តំលៃនៃផលិតផល និង ទ្រព្យទាំងនោះ រឺ កំមូលនិធិដែលបានមកពីការលក់នូវផលិតផល រឺ ទ្រព្យទាំងនោះ រឺក៏ចំណែកសំខាន់ណាមួយនៃតំលៃផលិតផល និង ទ្រព្យទាំងនោះ ជូនទៅ អង្គការអន្តររដ្ឋាភិបាលមានឯកទេសខាងការប្រយុទ្ធប្រឆាំងនឹងការចរាចរខុសច្បាប់ និង ការប្រើបំពានគ្រឿងញៀននិង សារធាតុប៉ះពាល់ប្រពន្ធ័សរសៃប្រសាទ

ii) ការផ្លាស់ប្តូរជាមួយភាគីដទៃទៀតជាប្រចាំ ឬ តាមករណីនីមួយៗ នូវផលិតផល ឬ ទ្រព្យទាំងនោះ រឺក៏មូលនិធិដែលបានមកពីការលក់នូវផលិតផល រឺទ្រព្យទាំងនោះ ដោយអនុលោមតាមច្បាប់ក្នុងប្រទេស តាមនីតិវិធីរដ្ឋបាលរបស់ខ្លួន រឺ តាមកិច្ចព្រមព្រៀងទ្វេភាគី រឺ ពហុភាគីដែលបានធ្វើអោយមានសំរាប់គោលបំណងនេះ ។

៦. ក) បើប្រសិនជា ផលិតផលត្រូវបានបំលែង រឺ ផ្លាស់ប្តូរទៅជាទ្រព្យរបស់ផ្សេងទៀត ទ្រព្យទាំងនោះត្រូវយកជាកម្មវត្ថុក្នុងការអនុវត្តវិធានការផ្សេងៗ ដូចមានចែងនៅក្នុងមាត្រានេះ ជំនួសផលិតផលទាំងនោះ

ខ) បើប្រសិនជា ផលិតផលមាននៅឡូកឡំជាមួយនឹងទ្រព្យដែលបាន មកពីប្រភពស្របច្បាប់ ដោយគ្មានលំអៀងដល់អំណាចខាងការឃាត់ទុករឺខាងការផ្អាកទេទ្រព្យទាំងនោះ អាចត្រូវរឹបអូសយកបានត្រឹមករិតតំលៃប៉ាន់ស្មាននៃ ផលិតផលដែលមាននៅឡូកឡំក្នុងនោះ

គ) ប្រាក់ចំណូល និងអត្ថប្រយោជន៏ដទៃទៀត :

i) ដែលបានមកពីផលិតផល

ii) ដែលបានមកពីទ្រព្យ ដែលនៅក្នុងនោះ ផលិតផលទាំងនោះ ត្រូវបានបំលែងរឺ ផ្លាស់ប្តូរ រឺ

iii) ដែលបានមកពីទ្រព្យដែលមានឡូកឡំផលិតផលក្នុងនោះ ក៏អាចយកជាកម្មវត្ថុក្នុងការអនុវត្តវិធានការដូចមានចែងក្នុងមាត្រានេះតាមរបៀបដូចគ្នា និងក្នុងករិតដូចគ្នានឹងផលិតផលដែរ ។

៧. ភាគីនីមួយៗ អាចយកមកពិនិត្យដោយទាត់ចោលការសន្មត់របស់ភស្តុតាង ចំពោះផលិតផលទាំងឡាយដែលគេបាន ចាត់ទុកពីមុនមកហើយថាមានដើមកំណើតស្របច្បាប់ រឺ ចំពោះទ្រព្យដទៃទៀតដែលជាកម្មវត្ថុនៃការរឹបអូសបានតែក្នុងករណីដែលកិច្ចការនោះ ស្របនឹងគោលការណ៏នៃច្បាប់ក្នុងប្រទេសរបស់ខ្លួន និង ស្របតាមល័ក្ខខ័ណ្ឌផ្ទាល់នៃនីតិវិធីតុលាការ និង នៃនីតិវិធីដទៃទៀត ។

៨. ការបកស្រាយបទបញ្ញត្តិទាំងឡាយនៃមាត្រានេះ មិនត្រូវឱ្យប៉ះពាល់ ទោះជាក្នុងករណីណាក៏ដោយដល់សិទ្ធិរបស់ភាគីដ៏សុទ្ធចិត្តទីបីឡើយ ។

៩. គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះ ធ្វើឱ្យប៉ះពាល់ដល់គោលការណ៍ ដែលយោងតាមគោលការណ៍នោះមានចែងពីវិធានការទាំងឡាយ ដែលត្រូវបានកំណត់ និងត្រូវបានអនុវត្តស្របទៅតាមច្បាប់ក្នុងប្រទេសនៃភាគីនីមួយៗ និងតាមបទបញ្ញត្តិច្បាប់ក្នុងប្រទេសនីមួយៗនោះទេ ។

## មាត្រា៦ : បត្យាប័ន

១. មាត្រានេះអនុវត្តបានចំពោះបទល្មើសផ្សេងៗដូចបានលើកឡើងពីសំណាក់ភាគីទាំងឡាយ ដោយអនុលោមតាមកថាខ័ណ្ឌ១ នៃមាត្រា៣ ។

២. បទល្មើសនីមួយៗដែលមាត្រានេះអាចយកមកអនុវត្តបាន ត្រូវតែមានសិទ្ធិយ៉ាងពេញលេញបញ្ចូលក្នុងគ្រប់សន្ធិសញ្ញាបត្យាប័ន ដែលមានជាធរមានទាំងអស់រវាងភាគីទាំងឡាយ ក្នុងឋានៈជាបទល្មើសដែលជនល្មើសអាចធ្វើបត្យាប័នបាន ។ ភាគីទាំងឡាយត្រូវសន្យាបញ្ចូលបទល្មើសទាំងនោះ ក្នុងឋានៈជាបទល្មើស ដែលជនល្មើសអាចធ្វើបត្យាប័នបាន ទៅក្នុងសន្ធិសញ្ញាបត្យាប័នទាំងអស់ដែលភាគីទាំងនោះនឹងត្រូវធ្វើឱ្យមាន។

៣. បើប្រសិនជាភាគីមួយ ធ្វើបត្យាប័នបានទាល់តែមានសន្ធិសញ្ញាបានទទួលនូវសំណើមួយសំរាប់ការផ្ដល់បត្យាប័នពីភាគីម្ខាងទៀតដែលពុំបានធ្វើឱ្យសន្ធិសញ្ញាបត្យាប័នបែបនេះ ភាគីនោះអាចចាត់ទុកអនុសញ្ញានេះជាមូលដ្ឋានស្របច្បាប់ចំពោះបត្យាប័ននៃបទល្មើសដែលមាត្រានេះ អាចយកមកអនុវត្តបាន ។ ភាគីដែលត្រូវការចាំបាច់នូវវិធានការច្បាប់លំអិតពិស្ដារដើម្បីអាចប្រើប្រាស់អនុសញ្ញានេះបាន ក្នុងឋានៈជាមូលដ្ឋានច្បាប់បត្យាប័ននោះនឹងយកមកពិនិត្យអនុម័តវិធានការផ្សេងៗប្រភេទបែបនោះ។

៤. ភាគីទាំងឡាយណាដែលធ្វើបត្យាប័នបានដោយមិនចាំបាច់មានសន្ធិសញ្ញាមួយ ត្រូវទទួលស្គាល់រវាងគ្នានូវបទល្មើសផ្សេងៗដែលមាត្រានេះអនុវត្តបាន នូវចរិតបទល្មើស ដែលជនល្មើសអាចធ្វើបត្យាប័នបាន ។

៥. បត្យាប័នត្រូវតែចំណុះលក្ខខណ្ឌដូចមានចែងនៅក្នុងច្បាប់របស់ភាគីទទួលសំណើ រឺ ចំណុះលក្ខខណ្ឌដូចមានចែងនៅក្នុងសន្ធិសញ្ញាបត្យាប័នផ្សេងៗដែលអាចអនុវត្តបាន ដែលមានរួមទាំងមូលហេតុផ្សេងៗដែលភាគីទទួលសំណើអាចប្រកែកមិនព្រមផ្ដល់បត្យាប័នផងដែរ ។

៦. កាលបើមានការពិចារណាទៅលើសំណើដែលបានទទួលដោយអនុវត្តមាត្រានេះ ភាគីទទួលសំណើអាចប្រកែកមិនព្រមធ្វើតាមសំណើនោះបាន បើប្រសិនជាអាជ្ញាធរតុលាការ រឺ អាជ្ញាធរមានសមត្ថកិច្ចដទៃទៀត របស់ខ្លួនមានមូលហេតុច្បាស់លាស់គិតឃើញថាការធ្វើបត្យាប័ននោះនឹងជួយសំរួលដល់ការធ្វើការចោទប្រកាន់ រឺ ការដាក់ទណ្ឌកម្មព្រហ្មទណ្ឌដល់បុគ្គលណាម្នាក់ដោយសារមូលហេតុប្រកាន់ ពូជសាសន៍ សាសនា សញ្ជាតិ រឺ មតិនយោបាយ រឺក៏ការធ្វើបត្យាប័ននោះ នឹងនាំឱ្យមានការលំអៀង ដល់មូលហេតុណាមួយនោះ លើបុគ្គលណាម្នាក់ដូចបានចោទប្រកាន់នៅក្នុងសំណើនោះ ។

៧. ភាគីទាំងឡាយ ត្រូវខិតខំជំរុញអោយនីតិវិធីបត្យាប័នមានសន្ទុះខ្លាំង និង ត្រូវគិតធ្វើយ៉ាងណាឱ្យងាយនូវតំរូវការភស្តុតាងផ្សេងៗ ដែលពាក់ពន្ធ័ទៅនឹងនីតិវិធីបត្យាប័ននេះចំពោះបទល្មើសដែលដែលអាចប្រើប្រាស់មាត្រានេះបាន ។

៨. លើកលែងតែមានបទបញ្ញត្តិនៃច្បាប់ក្នុងប្រទេស និង សន្ធិសញ្ញាបត្យាប័ន ដែលភាគីបានធ្វើរួចហើយ ដោយមានសំណើពីភាគីដាក់សំណើ ហើយប្រសិនបើភាគីទទួលសំណើយល់ឃើញថា កាលៈទេសៈតំរូវអោយមាន និងជាបន្ទាន់នោះ ភាគីទទួលសំណើអាចឃុំបុគ្គលដែលមានវត្តមានលើទឹកដីរបស់ខ្លួនទុកដែលបត្យាប័នបានស្នើ រឺក៏អាចចាត់វិធានការសមស្របផ្សេងៗទៀតចំពោះបុគ្គលនោះ ដើម្បីរ៉ាប់រងឱ្យមានវត្តមានរបស់បុគ្គលនោះក្នុងពេលធ្វើនីតិវិធីបត្យាប័ន ។

៩. គ្មានការលំអៀងដល់ការអនុវត្តសមត្ថកិច្ចព្រហ្មទណ្ឌ ដូចមានចែងស្របតាមច្បាប់ក្នុងប្រទេសរបស់ខ្លួនទេ ភាគីណាមួយដែលនៅលើទឹកដីរបស់ខ្លួនមានវត្តមានជនល្មើស ដែលគេបានចាត់ទុកថាប្រព្រឹត្តបទល្មើសត្រូវ :

ក) បញ្ជូនករណីនោះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើបណ្តឹងអាជ្ញា លើកលែងតែមានការព្រមព្រៀងផ្សេងទៀត ជាមួយភាគីដាក់សំណើ បើប្រសិនជាភាគីនោះមិនព្រមធ្វើបត្យាប័នបញ្ជូនជនល្មើសនោះ ចំពោះបទល្មើសដូចបានលើកឡើងក្នុងកថាខ័ណ្ឌ ១ នៃមាត្រា ៣ ដោយសារមូលហេតុដូចមានចែងនៅក្នុង វគ្គ ក កថាខ័ណ្ឌ២ នៃមាត្រា ៤

ខ) បញ្ជូនករណីនោះ ទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើបណ្តឹងអាជ្ញា លើកលែងតែមានសំណើដោយភាគីដាក់សំណើមានផ្សេងពីនេះ ក្នុងគោលដៅការពារសមត្ថកិច្ចត្រឹមត្រូវតាមច្បាប់របស់ខ្លួន បើប្រសិនជាភាគីនោះមិនព្រមធ្វើបត្យាប័នអោយជនល្មើសនោះ ចំពោះបទល្មើសនោះ ហើយភាគីនោះបានបង្កើតសមត្ថកិច្ចរបស់ខ្លួន សំរាប់បទល្មើសនោះ ដោយអនុលោមតាមវគ្គ ខ កថាខ័ណ្ឌ ២ នៃមាត្រា៤ ។

១០. បើប្រសិនជាបត្យាប័នស្នើសុំយកបុគ្គលមកធ្វើទោស ត្រូវបានប្រកែកមិនព្រមផ្តល់ ដោយមូលហេតុថា ជនដែលគេប្តឹងទាមទារនោះ ជាជនជាតិរបស់ភាគីទទួលសំណើ ហើយបើប្រសិនជាច្បាប់របស់ប្រទេសភាគីខ្លួនអនុញ្ញាត ហើយស្របតាមអាជ្ញាយុកាលនៃច្បាប់នោះ និងស្របតាមសំណើរបស់ភាគីដាក់សំណើផង ភាគីទទួលសំណើនឹងយកមកពិនិត្យដោយខ្លួនឯង ដើម្បីធ្វើការអនុវត្តទោសដែលបានកាត់រួចហើយស្របតាមច្បាប់របស់ភាគីដាក់សំណើនោះ រឺក៏ធ្វើការអនុវត្តទោសសំណល់នៃទោសនោះ ។

១១. ភាគីទាំងឡាយ ត្រូវខិតខំប្រឹងប្រែង ធ្វើឱ្យមានកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី ដើម្បីអាចធ្វើបត្យាប័នបាន រឺ ដើម្បីបង្កើនប្រសិទ្ធភាពនៃបត្យាប័ន ។

១២. ភាគីទាំងឡាយ អាចយកមកពិនិត្យធ្វើឱ្យមានកិច្ចព្រមព្រៀងទ្វេភាគី រឺ ពហុភាគី ស្តីពីចំនុចពិសេស រឺ ចរិតទូទៅដែលទាក់ទងនឹងការផ្ទេរមកកាន់ប្រទេសរបស់ជននោះវិញនូវជនដែលបានផ្តន្ទាទោសអោយជាប់ពន្ធនាគារ រឺ ទោសដកហូតសេរីភាពដទៃទៀត ចំពោះចំណុចសំខាន់បទល្មើសទាំងឡាយដែលមាត្រានេះ អាចយកមកអនុវត្តបានដើម្បីឱ្យជនទាំងនោះអាចទទួលទោសដែលនៅសល់របស់ខ្លួននៅក្នុងប្រទេសរបស់ជននោះ ។

## មាត្រា៧ : ការជួយគ្នាទៅវិញទៅមកខាងតុលាការ

១. អនុលោមតាមមាត្រានេះ ភាគីទាំងឡាយត្រូវព្រមព្រៀងគ្នាទៅវិញទៅមក ឱ្យមានការជួយគ្នាទៅវិញទៅមកដ៏ទូលំទូលាយ ចំពោះរាល់ការស៊ើបអង្កេត ការចោទប្រកាន់ និងនីតិវិធីតុលាការដែលពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌទាំងឡាយ ដូចមានចែង អនុលោមតាមកថាខ័ណ្ឌ១នៃ មាត្រា៣។

២. ការជួយគ្នាទៅវិញទៅមកខាងតុលាការ ដែលត្រូវបានព្រមព្រៀងគ្នា ដោយអនុវត្តតាមមាត្រានេះ អាចទាមទារបានក្នុងគោលដៅដូចតទៅ ÷

ក) ប្រមូលភស្តុតាង រឺ ចំលើយសាក្សី

ខ) ជូនដំណឹងតាមអាជ្ញាសាលា នូវលិខិតតុលាការ

គ) ធ្វើការឆែកឆេរ និងការរឹបអូស

ឃ) ពិនិត្យវត្ថុ និងទៅពិនិត្យទីកន្លែង

ង) ផ្តល់ពត៌មាន និង វត្ថុតាង

ច) ផ្តល់ច្បាប់ដើម រឺ ច្បាប់ចម្លងមានបញ្ជាក់ថាត្រឹមត្រូវតាមឯកសារ និងសំណុំរឿងសមហេតុផលទាំងឡាយ មានរួមទាំងសម្រង់ធនាគារ ឯកសារគណនេយ្យ សំណុំរឿងរបស់ក្រុមហ៊ុន និងឯកសារពាណិជ្ជកម្ម

ឆ) ធ្វើអត្តសញ្ញាណ រឺរាវរកផលិតផល ទ្រព្យ ឧបករណ៍ រឺ របស់របរផ្សេងទៀតដើម្បីប្រមូលធាតុនៃភស្តុតាង ។

៣. ភាគីទាំងឡាយអាចព្រមព្រៀងជាមួយគ្នា លើរាល់ទំរង់ជួយគ្នាទៅវិញទៅមកខាងតុលាការដែលអនុញ្ញាត ដោយច្បាប់ក្នុងប្រទេសនៃភាគីទទួលសំណើ ។

៤. នៅមានសំណើ ក្នុងករណីចុះសំរុងជាមួយនឹងច្បាប់របស់ខ្លួន ព្រមទាំងចុះសំរុងជាមួយនឹងការធ្លាប់អនុវត្តផ្ទៃក្នុងរបស់ខ្លួនស្រួលមកហើយ ភាគីត្រូវជួយសំរួល រឺជួយលើកទឹកចិត្តឱ្យមានវត្តមាន រឺ អោយមានត្រៀមទុកបំរុងបុគ្គលផ្សេងៗ រួមទាំងជនជាប់ឃុំដែលសុខចិត្តជួយជ្រោមជ្រែងក្នុងការស៊ើបអង្កេត រឺក៏ចូលរួមក្នុងនីតិវិធីតុលាការ ។

៥. ភាគីមិនអាចសំអាងទៅលើការសំងាត់របស់ធានាគារប្រកែកមិនព្រមជួយគ្នាទៅវិញទៅមក ខាងតុលាការដូចមានចែងក្នុងមាត្រានេះបានទេ ។

៦. បទបញ្ញត្តិនៃមាត្រានេះ មិនធ្វើឱ្យខូចដល់កាតព្វកិច្ច ដែលមានក្នុងសន្ធិសញ្ញាទ្វេភាគី រឺ ពហុភាគីដទៃទៀតដែលកំពុងគ្រប់គ្រង រឺ ដែលនឹងគ្រប់គ្រងទាំងស្រុង រឺ ដោយផ្នែកលើការងារជួយគ្នាទៅវិញទៅមកខាងតុលាការព្រហ្មទណ្ឌសោះឡើយ ។

៧. កថាខ័ណ្ឌ៨ ដល់ ១៥ នៃមាត្រានេះ អាចយកមកអនុវត្តបានចំពោះសំណើដែលធ្វើឡើង អនុលោមតាមមាត្រានេះ បើប្រសិនជាភាគីទាំងឡាយនៃបញ្ហានេះ មិនមានជាប់កាតព្វកិច្ចគ្នា ដោយសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកខាងតុលាការទេនោះ ។ បើប្រសិនជាភាគីទាំងនោះត្រូវបានជាប់កាតព្វកិច្ចជាមួយគ្នាដោយសន្ធិសញ្ញាប្រភេទបែបនេះនោះ បទបញ្ញត្តិដែលត្រូវគ្នានឹងកថាខ័ណ្ឌរបស់សន្ធិសញ្ញានោះអាចអនុវត្តបាន លើកលែងតែភាគីទាំងនោះព្រមអនុវត្តជំនួសបទបញ្ញត្តិ ពីកថា ខ័ណ្ឌទី៨ រហូត ដល់ទី១៥ នៃមាត្រានេះប៉ុណ្ណោះ ។

៨. ភាគីត្រូវចាត់តាំងអាជ្ញាធរមួយ រឺ បើប្រសិនជាចាំបាច់គួរ គឺត្រូវចាត់តាំងអាជ្ញាធរច្រើន ដែលមានការទទួលខុសត្រូវ និងមានអំណាចក្នុងការឆ្លើយតបទៅនឹងសំណើឱ្យមានការជួយគ្នាទៅវិញទៅមកខាងតុលាការ រឺក៏មានអំណាចបញ្ជូនសំណើទាំងនោះទៅអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗដើម្បីអនុវត្តន៍ ។

អាជ្ញាធរមួយ រឺ ច្រើនដែលបានចាត់តាំងសំរាប់គោលបំណងនេះ ត្រូវជាកម្មវត្ថុនៃលិខិតជូនដំណឹងជំរាបទៅអគ្គលេខាធិការ ។ ការបញ្ជូនសំណើឱ្យមានការជួយគ្នាទៅវិញទៅមកខាងតុលាការ និង សំណើសុំឱ្យមានការទាក់ទងគ្នាពាក់ព័ន្ធទៅនឹងកិច្ចការនេះត្រូវធ្វើឡើងតាមរយៈ អាជ្ញាធរដែលបានចាត់តាំងដោយភាគីទាំងនោះ បទបញ្ញត្តិមួយនេះត្រូវបកស្រាយគ្មានលំអៀងដល់សិទ្ធិរបស់រាល់ភាគីដែលតំរូវឱ្យមានសំណើទាំងនេះ និងការទាក់ទងផ្សេងៗជាមួយនឹងខ្លួនគេ ធ្វើ តាមរយៈមធ្យោបាយ ការទូតនោះទេហើយនៅក្នុងករណីបន្ទាន់បើប្រសិនជាភាគីទាំងនោះសន្មត់យក ហើយបើប្រសិនជាកិច្ចការនេះអាចធ្វើបានគឺធ្វើតាមរយៈ OIPC/ Interpol អង្គការប៉ូលីសខាងបទ ឧក្រិដ្ឋអន្តរជាតិ ។

៩. សំណើត្រូវធ្វើជាលាយល័ក្ខអក្សរ ជាភាសាដែលភាគីទទួលសំណើទទួលយកបាន ។ ភាសាមួយ រឺ ភាសាច្រើន ដែលទទួលយកបានពីសំណាក់ភាគីនីមួយៗត្រូវជូនដំណឹងជាលាយល័ក្ខអក្សរទៅអគ្គលេខាធិការ។ ក្នុងករណីបន្ទាន់ហើយបើប្រសិនជាភាគីទាំងនោះព្រមព្រៀងយកបណ្ដឹងទាមទារអាចធ្វើដោយផ្ទាល់មាត់បាន ប៉ុន្តែត្រូវតែអះអាងបញ្ជាក់បន្ថែមភ្លាមជាលាយល័ក្ខអក្សរ ។

១០. សំណើអោយមានការជួយគ្នាទៅវិញទៅមកខាងតុលាការ ត្រូវមានលក្ខណៈដូចតទៅ :

ក) ការចាត់តាំងអាជ្ញាធរអោយធ្វើសំណើ

ខ) កម្មវត្ថុ និងលក្ខណៈនៃការស៊ើបអង្កេតនៃការចោទប្រកាន់ព្រហ្មទណ្ឌ រឺ នៃនីតិវិធីតុលាការដែលទាក់ទងទៅនឹងសំណើ និង ឈ្មោះ ព្រមទាំងមុខងារផ្សេងៗរបស់អាជ្ញាធរដែលទទួលបន្ទុកការងារទាំងនោះ

គ) សេចក្ដីសង្ខេបពីហេតុការណ៍ផ្សេងៗដែលសមហេតុផល លើកលែងតែចំពោះសំណើដែលផ្ញើដើម្បីជូនដំណឹងតាមរយៈអាជ្ញាសាលាន្ទូវលិខិតតុលាការ

ឃ) សេចក្ដីអធិប្បាយពីជំនួយទំនុកបំរុងដែលទាមទារ និង សេចក្ដីលំអិត នៃរាល់នីតិវិធីពិសេសដែលភាគីដាក់សំណើមានសំណូមពរអោយអនុវត្ត

ង) អត្តសញ្ញាណ អាសយដ្ឋាន និង សញ្ជាតិរបស់បុគ្គលដែលភាគីបានដៅទុកនោះ បើប្រសិនជាមានលទ្ធភាព

ច) គោលបំណង ដែលនៅក្នុងនោះមាន ភស្តុតាង ពត៌មានផ្សេងៗ រឺ វិធានការផ្សេងៗ ដែលបានគិតទុក។

១១. ភាគីទទួលសំណើ អាចទាមទារពត៌មានបន្ថែមទៀត កាលបើពត៌មានបន្ថែមនោះ ហាក់ដូចជាចាំបាច់សំរាប់អនុវត្តសំណើ ស្របតាមច្បាប់របស់ប្រទេសខ្លួន រឺក៏ កាលបើពត៌មានបន្ថែមនោះ អាចជួយសំរួល

ដល់ការអនុវត្តសំណើបាន ។

១២. រាល់សំណើត្រូវអនុវត្ត អនុលោមតាមច្បាប់របស់ភាគីទទួលសំណើ ក្នុងករណីដែល សំណើ មិនផ្ទុយនឹងច្បាប់ដូចបានពោលនោះ ហើយកាលបើសំណើផ្ទុយនឹងច្បាប់របស់ភាគីទទួលសំណើវិញនោះ សំណើត្រូវអនុវត្តអនុលោមតាមនីតិវិធីដែលបានបញ្ជាក់នៅក្នុងសំណើនោះ ។

១៣. ភាគីដាក់សំណើមិនអាចបញ្ជូនពតិមាន ទាំងមិនអាចប្រើពតិមាន រឺ ក៏ភស្តុតាងដែលភាគីទទួលសំណើបានផ្តល់អោយសំរាប់ការស៊ើបអង្កេត ការចោទប្រកាន់ព្រហ្មទណ្ឌ រឺ នីតិវិធីតុលាការណា ក្រៅផ្សេងពីការស៊ើបអង្កេត ការចោទប្រកាន់ព្រហ្មទណ្ឌ រឺ នីតិវិធីតុលាការ ដូចមានចែងនៅក្នុងសំណើដោយគ្មានការព្រមព្រៀងជាមុន ពីភាគីទទួលសំណើបានទេ ។

១៤. ភាគីដាក់សំណើអាចតំរូវអោយភាគីទទួលសំណើ រក្សាសំងាត់លើសំណើ និង សេចក្តីនៃសំណើនោះ លើកលែងតែក្នុងករណីដើម្បីឱ្យអនុវត្តបណ្តឹងទាមទារនោះជាចាំបាច់ ។ បើប្រសិនជាភាគីទទួលសំណើមិនអាចតំរូវចិត្តរក្សាការសំងាត់នេះបាន ភាគីនោះត្រូវផ្តល់ពតិមានភ្លាមជាបន្ទាន់ពីបញ្ហានេះ ទៅឱ្យភាគីដាក់សំណើ ។

១៥. ការជួយគ្នាទៅវិញទៅមកខាងតុលាការ អាចប្រកែកមិនធ្វើបាន :

ក) បើប្រសិនជា សំណើធ្វើឡើងមិនបានត្រឹមត្រូវទៅតាមបទបញ្ញត្តិនៃមាត្រានេះ

ខ) បើប្រសិនជាភាគីទទួលសំណើប្រមាណទៅឃើញថា ការអនុវត្តសំណើនោះអាច ប៉ះពាល់ដល់អធិបតេយ្យភាព ដល់សន្តិសុខ ដល់របៀបរាបរយសាធារណៈ រឺ ដល់ផលប្រយោជន៍ សំខាន់ៗដទៃទៀតរបស់ខ្លួន

គ) ក្នុងករណីច្បាប់របស់ភាគីទទួលសំណើ ហាមឃាត់មិនអោយអាជ្ញាធរទាំងឡាយរបស់ខ្លួនអនុវត្តវិធានការដូចដែលបានស្នើសុំនោះ បើប្រសិនជាវាជារឿងបទល្មើសមួយស្រដៀងគ្នាដែលបានយកមកធ្វើជាកម្មវត្ថុនៃការស៊ើបអង្កេត ការចោទប្រកាន់ព្រហ្មទណ្ឌ រឺ នីតិវិធីតុលាការក្នុងក្របខ័ណ្ឌសមត្ថកិច្ចផ្ទាល់របស់អាជ្ញាធរទាំងនោះ

ឃ) ក្នុងករណីផ្ទុយនឹងប្រព័ន្ធគតិយុត្ត នៃភាគីទទួលសំណើ ក្នុងការទទួលយកសំណើ ដែលទាក់ទងនឹងការជួយគ្នាទៅវិញទៅមកខាងតុលាការ ។

១៦. រាល់ការប្រកែកមិនព្រម ជួយគ្នាទៅវិញទៅមកខាងតុលាការ ត្រូវតែមានមូលហេតុ ។

១៧. ភាគីទទួលសំណើ អាចពន្យារពេលការជួយគ្នាទៅវិញទៅមកខាងតុលាការបាន ដោយសារមូលហេតុការជួយគ្នាទៅវិញទៅមកខាងតុលាការការនេះ នឹងធ្វើអោយប៉ះពាល់ដល់ការស៊ើបអង្កេតមួយ ដល់ការចោទប្រកាន់ព្រហ្មទណ្ឌផ្សេងៗ រឺ ដល់នីតិវិធីតុលាការមួយដែលកំពុងតែដំណើរការ ។ ក្នុងករណីបែបនេះ ភាគីទទួលសំណើ ត្រូវពិគ្រោះជាមួយភាគីដាក់សំណើ ដើម្បីបញ្ជាក់ថាការជួយគ្នាទៅវិញទៅមកនេះ អាចនៅតែផ្តល់ជូនក្នុងល័ក្ខខ័ណដែលភាគីទទួលសំណើថាចាំបាច់នោះ ។

១៨. សាក្សី អ្នកជំនាញ រឺបុគ្គលឯទៀត ដែលយល់ព្រមឆ្លើយអោយការណ៍នៅពេលដំណើរការនីតិវិធីមួយ រឺ យល់ព្រមសហការជួយស៊ើបអង្កេត ជួយចោទប្រកាន់ព្រហ្មទណ្ឌ រឺ ជួយធ្វើនីតិវិធីតុលាការនៅលើទឹកដី នៃភាគីដាក់សំណើ ជននោះមិនត្រូវបានចោទប្រកាន់ ជាប់ឃុំ រឺ ដាក់ទោស រឺមិនត្រូវរងការបន្ថយក៏រិតព្រំដែនសេរីភាពផ្ទាល់ខ្លួនដទៃទៀត នៅលើទឹកដីនោះទេ ចំពោះអំពើ ការលុបចោល រឺការកាត់ទោសផ្សេងៗ ដែលមានមកនៅមុនពេលចេញដំណើរពីទឹកដីនៃភាគីទទួលសំណើ ។ អភ័យឯកសិទ្ធិនេះនឹងត្រូវផុតរលត់ កាលបើសាក្សី អ្នកជំនាញ រឺបុគ្គលដូចបានពោលនោះ មានលទ្ធភាពចាកចេញពីទឹកដីប៉ុន្តែមានចេតនា ឋិតនៅ រឺបានចាកចេញផុតពីទឹកដីហើយ ត្រលប់មកវិញដោយស្ម័គ្រចិត្ត ក្នុងរយៈពេល ១៥ ថ្ងៃជាប់ៗ គ្នា រឺ ក្នុងរយៈពេលមួយផ្សេងទៀត ដែលភាគីទាំងនោះបានព្រមព្រៀងគ្នាគិត ចាប់តាំងពីកាលបរិច្ឆេទ ដែលអ្នកទាំងនោះ ត្រូវបានអាជ្ញាធរតុលាការជូនដំណឹងជាផ្លូវការថា វត្តមានរបស់អ្នកទាំងនោះលែងត្រូវទាមទារទៀតហើយ ។

១៩. សោហ៊ុយធម្មតាផ្សេងៗ ដែលមានសំរាប់ធ្វើប្រតិបត្តិការសំណើណាមួយ ជាបន្ទុករបស់ភាគីទទួលសំណើ លើកលែងតែមានការព្រមព្រៀងផ្សេងរវាងភាគីដែលពាក់ព័ន្ធ។ កាលបើចំណាយផ្សេងៗមានច្រើន រឺ ជាពិសេសៗត្រូវមាន រឺ ពាក់ព័ន្ធក្រោយមកទៀតជាចាំបាច់ដើម្បីធ្វើប្រតិបត្តិការសំណើនោះភាគីទាំងនោះត្រូវពិគ្រោះគ្នា ដើម្បីកំណត់ល័ក្ខខ័ណ្ឌ ដែលនៅក្នុងនោះសំណើនឹងត្រូវធ្វើប្រតិបត្តិការព្រមទាំងរបៀបដែលសោហ៊ុយចំណាយទាំងនោះនឹងត្រូវចេញ ។

២០. បើចាំបាច់ត្រូវធ្វើភាគីត្រូវយកមកពិនិត្យ នូវលទ្ធភាពធ្វើឱ្យមានកិច្ចព្រមព្រៀង រឺកិច្ចសំរុះសំរួលទ្វេភាគី រឺ ពហុភាគី ដែលបំរើអោយគោលដៅនៃបទបញ្ញត្តិមាត្រានេះ និងផ្តល់អោយការអនុវត្តបទបញ្ញត្តិនេះមានភាពស្រួលប្រើ រឺ ពង្រឹងបទបញ្ញត្តិទាំងនោះថែមទៀត ។

## មាត្រា៨ : ការផ្ទេរនីតិវិធីបង្ក្រាប

ភាគីទាំងឡាយត្រូវពិនិត្យ នូវលទ្ធភាពផ្ទេរនីតិវិធីបង្ក្រាបទៅវិញទៅមក ដែលទាក់ទងទៅនឹងបទ

ល្មើសដូចមានចែង អនុលោមតាមកថាខ័ណ្ឌ១ នៃមាត្រា៣ ក្នុងករណីដែលការផ្ទេរនេះចាំបាច់សំរាប់ជាផល ប្រយោជន៍ដល់ការធ្វើអោយរដ្ឋបាលយុត្តិធម៌បានល្អ ។

## មាត្រា៩ : ទម្រង់ដទៃទៀតនៃកិច្ចសហប្រតិបត្តិការនិងការបណ្តុះបណ្តាល

១. ដោយអនុលោមតាមប្រព័ន្ធគតិយុត្ត និងរដ្ឋបាលរបស់ភាគីរៀង១ខ្លួន ភាគីទាំងឡាយត្រូវសហ-ប្រតិបត្តិការជិតស្និទ្ធក្នុងចេតនាពង្រឹងប្រសិទ្ធភាពខាងសកម្មភាពរារាំងនិងបង្ក្រាប សំដៅបញ្ឈប់ការប្រព្រឹត្តបទល្មើស ដូចមានចែងស្របតាមកថាខ័ណ្ឌ១នៃមាត្រា៣ ។ ជាពិសេស ឈរលើមូលដ្ឋាននៃកិច្ចព្រមព្រៀង រឺ កិច្ច សំរុះសំរួលទ្វេភាគី រឺ ពហុភាគី :

ក) ភាគីទាំងនោះត្រូវបង្កើត និង ត្រូវរក្សាទុកមធ្យោបាយទាក់ទង រវាងអង្គការមានសមត្ថកិច្ចផ្សេង១ និង អង្គភាពជាតិមានសមត្ថកិច្ចផ្សេង១ ក្នុងចេតនាជួយសំរួលដល់ការផ្លាស់ប្តូរដំណឹងអោយការណ៍ផ្សេង១អោយបានប្រាកដ និង បានរហ័ស ចំពោះបទល្មើសគ្រប់ទិដ្ឋភាពដូចមានចែងស្របតាមកថាខ័ណ្ឌ១ នៃមាត្រា ៣ មានរួមទាំងទំនាក់ទំនងនៃចរាចរនេះជាមួយនឹងសកម្មភាពដែលជាបទមជ្ឈឹមដទៃទៀតបើប្រសិនជាភាគីសាមីទាំងនោះយល់ថាសមស្រប

ខ) ភាគីទាំងឡាយត្រូវធ្វើសហប្រតិបត្តិការជាមួយគ្នា ចំពោះបទល្មើសដូចមានចែងស្របតាមកថាខ័ណ្ឌ១ នៃមាត្រា៣ ហើយដែលមានចរិតអន្តរជាតិ ដោយធ្វើការស៊ើបអង្កេតផ្សេង១ស្តីអំពី :

i) អត្តសញ្ញាណ ទីកន្លែងដែលមានវត្តមានជនជាប់សង្ស័យ និង សកម្មភាពដែលជនជាប់សង្ស័យប្រព្រឹត្តបទល្មើស ដូចមានចែងស្របតាម កថាខ័ណ្ឌ១ នៃមាត្រា៣

ii) ចលនានៃផលិតផល និង ទ្រព្យរបស់ ដែលបានមកពីការប្រព្រឹត្ត បទល្មើសដូចបានពោលនោះ

iii) ចលនានៃគ្រឿងញៀន សារធាតុប៉ះពាល់សរសៃប្រសាទ សារធាតុចុះបញ្ជី ក្នុងតារាងទី១ និង ក្នុងតារាងទី២នៃអនុសញ្ញានេះ និងឧបករណ៍ដែលប្រើប្រាស់ រឺ បំរុងនឹងប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសទាំងនោះ

គ) កាលបើមាន និងបើប្រសិនជាមិនផ្ទុយនឹងច្បាប់ក្នុងប្រទេសរបស់ខ្លួន ដោយគិតទាំងភាពចាំបាច់ក្នុងការការពារសន្តិសុខដល់បុគ្គល និងដល់កិច្ចប្រតិបត្តិការផង ភាគីទាំងឡាយត្រូវបង្កើតក្រុមចំរុះផ្សេង១ អោយទទួលបន្ទុកប្រើបទបញ្ញត្តិទាំងឡាយនៃកថាខ័ណ្ឌនេះដើម្បីអនុវត្តន៍ ។ ភ្នាក់ងាររបស់ភាគីនីមួយ១ដែលចូលជាសមាជិកនៃក្រុមប្រភេទនេះ ត្រូវធ្វើតាមការចង្អុលបង្ហាញរបស់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីដែលនៅលើទឹកដីនៃភាគីនោះ ត្រូវបង្កើតកិច្ចប្រតិបត្តិការ

ប្រព្រឹត្តទៅនៅគ្រប់ករណីទាំងនេះ ហើយភាគីសាមីទាំងនោះ ត្រូវចាំឃ្លាំមើលយ៉ាងណាអោយអធិបតេយ្យភាពរបស់ភាគី ដែលប្រតិបត្តិការមានដំណើរប្រព្រឹត្តទៅ នៅលើទឹកដីរបស់ខ្លួននោះត្រូវបានគោរពយ៉ាងពេញលេញ

ឃ) កាលបើមានភាគីទាំងនោះ ត្រូវផ្តល់នូវបរិមាណចាំបាច់នៃសារធាតុសំរាប់ធ្វើវិភាគ រឺ ស៊ើបអង្កេត

ង) ភាគីទាំងនោះ ត្រូវជួយសំរួល កិច្ចសហការអោយមានប្រសិទ្ធិភាព រវាងអង្គការមានសមត្ថកិច្ច និងអង្គភាពមានសមត្ថកិច្ចរបស់ខ្លួន និងលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរបុគ្គលិក និង អ្នកជំនាញទៅវិញទៅមក រួមទាំងការចាត់តាំងនូវភ្នាក់ងារដាក់អោយនៅក្រៅតំណែងសំរាប់ចាំធ្វើទំនាក់ទំនងទៀតផង ។

២. ក្នុងករណីចាំបាច់ ភាគីនីមួយៗត្រូវបង្កើត ពង្រីក រឺ ធ្វើអោយកាន់តែប្រសើរនូវកម្មវិធីបណ្តុះបណ្តាលតាមប្រភេទផ្សេងៗជាប្រយោជន៍ ដល់សមាជិកនៃអង្គភាពរបស់ខ្លួន ខាងការរាវរក និង ខាងការបង្ក្រាបរបស់ភាគីខ្លួន ហើយនិងបុគ្គលិកដទៃទៀត មានរួមទាំងភ្នាក់ងារគយដែលទទួលបន្ទុកបង្ក្រាបបទល្មើស ដូចមានចែងស្របតាមកថាខ័ណ្ឌ១នៃមាត្រា៣ផង ។ កម្មវិធីទាំងនេះត្រូវមានលើចំនុចដូចតទៅនេះ ជាអាទិ៍ :

ក) វិធីដែលយកទៅប្រើ ក្នុងការរាវរកនិងបង្ក្រាបបទល្មើសដូចមានចែងអនុលោមតាម កថាខ័ណ្ឌ១នៃមាត្រា៣

ខ) ផ្លូវទៅមកដែលប្រើប្រាស់ និងបច្ចេកទេសដែលប្រើ របស់ជនដែលជាប់សង្ស័យប្រព្រឹត្តបទល្មើស ដូចមានចែងស្របតាមកថាខ័ណ្ឌ១នៃមាត្រា៣ ពិសេសក្នុងរដ្ឋឆ្លងកាត់ ហើយនិងវិធានការប្រយុទ្ធដែលសមស្របផ្សេងៗ

គ) ការត្រួតពិនិត្យការនាំចូល និង ការនាំចេញនូវគ្រឿងញៀន សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង សារធាតុ ដូចមានចុះបញ្ជីក្នុងតារាងទី១ និង តារាងទី២ ;

ឃ) ការរាវរក និង ការត្រួតពិនិត្យ ចលនានៃផលិតផល និងទ្រព្យ ដែលបានមកពីការប្រព្រឹត្តបទល្មើស ដូចមានចែងអនុលោមតាមកថាខ័ណ្ឌ១នៃមាត្រា៣ និង ចលនានៃគ្រឿងញៀន សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ សារធាតុដូចមានចុះបញ្ជីក្នុងតារាងទី១ និង តារាងទី២ ព្រមទាំងឧបករណ៍ដែលប្រើប្រាស់ រឺ ដែលទុកសំរាប់ប្រើប្រាស់ ដើម្បីប្រព្រឹត្តបទល្មើសដូចបានពោលនោះ

ង) វិធីដែលប្រើសំរាប់ផ្ទេរ សំរាប់លាក់ រឺ សំរាប់ក្លែងផលិតផល, ក្លែងទ្រព្យ និង ក្លែងឧបករណ៍ទាំងនោះ

ច) ការប្រមូលធាតុទាំងឡាយនៃភស្តុតាង

ឆ) បច្ចេកទេសត្រួតពិនិត្យ ក្នុងតំបន់រួចពន្ធ និង កំពង់ផែរួចពន្ធ

ជ) បច្ចេកទេសទំនើប ខាងការរាវរក និងខាងការបង្ក្រាប ។

៣. ភាគីទាំងឡាយ ត្រូវជួយគ្នា ធ្វើផែនការ និងប្រតិបត្តិកម្មវិធីបណ្តុះបណ្តាល និង ស្រាវជ្រាវទៅវិញទៅមក អនុញ្ញាតអោយភាគីទាំងនោះ អាចផ្លាស់ប្តូរចំណេះដឹងឯកទេសក្នុងវិស័យនានា ដូចមានចែងនៅក្នុងកថាខ័ណ្ឌ២នៃមាត្រានេះ ហើយសំរាប់គោលបំណងនេះ ភាគីទាំងនោះត្រូវរៀបចំផងដែរកាលបើមានទូវសន្និសីទ និងសិក្ខាសាលាតំបន់ និង អន្តរជាតិដើម្បីជំរុញកិច្ចសហប្រតិបត្តិការ និង ដើម្បីបើកឱកាសឱ្យមានការពិនិត្យបញ្ហាផ្សេងៗដែលជាផលប្រយោជន៍រួម មានរួមទាំងបញ្ហាពិសេសៗ និងតំរូវការពិសេសៗរបស់រដ្ឋឆ្លងកាត់ទាំងឡាយផង ។

## មាត្រា១០ : កិច្ចសហប្រតិបត្តិការអន្តរជាតិ និងជំនួយទំនុកបំរុងដល់រដ្ឋឆ្លងកាត់

១. ភាគីទាំងឡាយត្រូវធ្វើសហប្រតិបត្តិការ ដោយផ្ទាល់ រឺ តាមរយៈអង្គការអន្តរជាតិ រឺអង្គការតំបន់មានសមត្ថកិច្ចផ្សេងៗ ក្នុងបំណងផ្តល់ជំនួយទំនុកបំរុងនិងជួយជាបង្អែកក្នុងករណីដែលមានលទ្ធភាពដល់រដ្ឋឆ្លងកាត់ និងជាពិសេស ដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលត្រូវការជំនួយទំនុកបំរុងប្រភេទបែបនេះ និង ជំនួយជាបង្អែកបែបនេះ តាមរយៈមធ្យោបាយកម្មវិធីសហប្រតិបត្តិការបច្ចេកទេស ដែលសំដៅហាមឃាត់ការចូល និងការឆ្លងកាត់ខុសច្បាប់ និងដែលពាក់ព័ន្ធទៅនឹងសកម្មភាពប្រទាក់ក្រឡាផ្សេងៗ ។

២. ភាគីទាំងឡាយ អាចផ្តើមធ្វើដោយផ្ទាល់ រឺ តាមរយៈអង្គការអន្តរជាតិ រឺ តំបន់មានសមត្ថកិច្ចផ្សេងៗ ដោយផ្តល់ជំនួយទំនុកបំរុងហិរញ្ញវត្ថុ ដល់រដ្ឋឆ្លងកាត់ទាំងនោះ សំរាប់អភិវឌ្ឍន៍ និងសំរាប់ពង្រឹងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការចរាចរខុសច្បាប់ និងដើម្បីបង្ការការចរាចរខុសច្បាប់នេះអោយមានប្រសិទ្ធភាព ។

៣. ភាគីទាំងឡាយ អាចធ្វើអោយស្រេចកិច្ចព្រមព្រៀង រឺ កិច្ចសំរុះសំរួលទ្វេភាគី រឺ ពហុភាគី ដើម្បីពង្រឹងប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការអន្តរជាតិ ដូចបានគ្រោងទុកក្នុងមាត្រានេះ ហើយនិងអាចយកមកពិនិត្យធ្វើអោយស្រេចកិច្ចសំរុះសំរួលផ្នែកហិរញ្ញវត្ថុត្រង់ចំនុចនេះ ។

## មាត្រា ១១ : ការប្រគល់ដោយមានការចាំឃ្លាំមើល

១. បើប្រសិនជាគោលការណ៍គ្រឹះនៃប្រព័ន្ធតតិយុត្ត ក្នុងប្រទេសរបស់ភាគីអនុញ្ញាត ភាគីត្រូវចាត់វិធានការចាំបាច់ផ្សេងៗក្នុងលទ្ធភាពរបស់ខ្លួន ដើម្បីអនុញ្ញាតអោយមានការប្រើសមស្របនូវការប្រគល់មានការចាំឃ្លាំមើលក៏រិតអន្តរជាតិ ឈរលើមូលដ្ឋាននៃកិច្ចព្រមព្រៀង រឺកិច្ចសំរុះសំរួលដែលភាគីទាំងនោះនឹងធ្វើឱ្យមានក្នុងបំណងធ្វើអត្តសញ្ញាណ ជនដែលចូលរួមក្នុងបទល្មើសផ្សេងៗ ដូចមានចែងស្រប តាម កថាខ័ណ្ឌ ១ នៃមាត្រា៣ និង ក្នុងបំណង ធ្វើការចោទប្រកាន់ប្រឆាំងនឹងជនទាំងនោះ ។

២. សេចក្តីសំរេចប្រើប្រាស់ ការប្រគល់មានការចាំឃ្លាំមើល ត្រូវធ្វើទៅតាមករណីដោយឡែកនីមួយៗ ហើយអាចប្រសិនជាត្រូវធ្វើ ត្រូវគិតពីកិច្ចសំរុះសំរួល និង កិច្ចព្រមព្រៀងគ្នាខាងហិរញ្ញវត្ថុក្នុងការប្រើសមត្ថកិច្ចរបស់ភាគីសាមី ដោយភាគីសាមីទាំងនោះ ។

៣. របស់ផ្ញើរខុសច្បាប់ផ្សេងៗ ដែលគេសន្មតថា ត្រូវតែចាំឃ្លាំមើលការប្រគល់ ដោយមានការព្រមព្រៀងពីភាគីសាមីផ្សេងៗ អាចត្រូវចាំស្ទាក់ចាប់ និង អនុញ្ញាតអោយបន្តការផ្ញើ ដោយទុករបស់ផ្ញើអោយនៅតាមលំនាំដើមគ្មានផ្លាស់ប្តូរ រឺមួយបន្តការផ្ញើក្រោយពីបានដកហូតខ្លះៗ រឺមួយក៏ជំនួសទាំងស្រុង រឺមួយចំនួនគ្រឿងញៀន រឺសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទនោះ ដោយផលិតផលផ្សេងវិញ ។

## មាត្រា ១២ : សារធាតុផ្សេងៗដែលប្រើប្រាស់ជាញឹកញាប់នៅក្នុងការផលិតដោយខុសច្បាប់នូវគ្រឿងញៀន រឺសារធាតុដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ

១. ភាគីទាំងឡាយត្រូវអនុម័តយកវិធានការផ្សេងៗ ដែលខ្លួនយល់ថាសមស្រប ដើម្បីទប់ស្កាត់ការបំបែរសារធាតុ ដូចមានចុះបញ្ជីតារាងទី១ និង តារាងទី២ ក្នុងគោលបំណងធ្វើគ្រឿងញៀនខុសច្បាប់ និងសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ព្រមទាំងត្រូវសហប្រតិបត្តិការជាមួយបណ្តាភាគីផ្សេងទៀតដើម្បីបញ្ចប់បញ្ហានេះ ។

២. បើប្រសិនជា ភាគីមួយ រឺ "ក្រុមប្រឹក្សា" មានពត៌មានដែលតាមយោបល់របស់ភាគី ចាំបាច់ត្រូវបញ្ចូលសារធាតុមួយទៅក្នុងតារាងទី១ រឺតារាងទី២នោះ ភាគីនោះ ត្រូវជំរាបជូនទៅអគ្គលេខាធិការ និងផ្តល់លិខិតជូនដំណឹងដោយមានភ្ជាប់ទៅជាមួយនូវពត៌មានសមហេតុផលទាំងអស់ សំរាប់ជាបង្អែកដល់លិខិតជូនដំណឹងនោះ ។ នីតិវិធីដូចរៀបរាប់ក្នុងកថាខ័ណ្ឌ២ ដល់ ៧ នៃមាត្រានេះ ក៏អាចយកមកអនុវត្ត

បានដែរកាលបើភាគី ឬ ក្រុមប្រឹក្សា មានពត៌មានបញ្ជាក់ពីការត្រូវលុបសារធាតុមួយចេញពីតារាងទី១ រឺ ពីតារាងទី២ រឺ ក៏ត្រូវផ្ទេរសារធាតុមួយពីតារាងមួយចូលទៅតារាងមួយទៀត ។

៣. អគ្គលេខាធិការត្រូវ ជំរាបជូនដំណឹងពីលិខិតនេះ និងពីពត៌មានទាំងអស់ នៅពេលដែលអគ្គលេខាធិការយល់ថាមានការពាក់ព័ន្ធទៅនឹងភាគីនានា ទៅ គណៈកម្មាការ ហើយបើប្រសិនជាលិខិតជូនដំណឹងនេះចេញមកពីភាគីវិញនោះត្រូវជូនទៅ "ក្រុមប្រឹក្សា" វិញ ។ ភាគីត្រូវជំរាបជូនទៅអគ្គលេខាធិការពីការសង្កេតរបស់ខ្លួន ចំពោះលិខិតជូនដំណឹងនេះ ព្រមទាំងពត៌មានបន្ថែមទាំង អស់ដែលមានចរិតពិសេសអាចជួយ "ក្រុមប្រឹក្សា" អោយបង្កើតនីតិវិធីសំរាប់យកទៅវាយតំលៃនិង ជួយ "គណៈកម្មការ" អោយធ្វើសេចក្ដីសំរេចបាន ។

៤. ដោយគិតពីវិសាលភាព សារៈសំខាន់ និងពីការប្រើប្រាស់ប្លែកៗគ្នាតាមលក្ខណៈស្របច្បាប់នូវសារធាតុ ហើយ និងក្រោយពីបានពិសោធរួចមក ឃើញថាទៅរួច ហើយងាយស្រួលក្នុងការប្រើសារធាតុជំនួសទាំងក្នុងបំណងបំណងស្របច្បាប់ រឺ ក៏ទាំងក្នុងការធ្វើខុសច្បាប់នូវគ្រឿងញៀន រឺ សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទបើ " ក្រុមប្រឹក្សា " សំគាល់ឃើញ÷

ក) ថា សារធាតុទាំងនោះ ត្រូវបានយកទៅប្រើប្រាស់ជាញឹកញាប់ ក្នុងការផលិតគ្រឿងញៀនខុសច្បាប់ រឺ សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង

ខ) ថា ការផលិតគ្រឿងញៀនខុសច្បាប់ រឺ សារធាតុប៉ះពាល់ប្រពន្ធ័សរសៃប្រសាទ មានទំហំ និងវិសាលភាពដែលនាំបង្កើតអោយមានបញ្ហាដ៏ធ្ងន់ធ្ងរប៉ះពាល់ដល់សុខភាពសាធារណៈរឺ ប៉ះពាល់ដល់សង្គមយ៉ាងធ្ងន់ធ្ងរ ដូច្នេះត្រូវចេញដីកាចាត់វិធានការជាអន្តរជាតិ ហើយបញ្ហានេះត្រូវជំរាបជូនទៅ "គណៈកម្មការ" ពីការវាយតំលៃសារធាតុនោះ ដោយចង្អុលប្រាប់ជាអាទិ៍ ពីផលដែលគួរមានការចុះបញ្ជីសារធាតុនោះ ក្នុងតារាងទី១ រឺ តារាងទី២ ទោះជាមានការប្រើប្រាស់ស្របច្បាប់ រឺ ក៏ការធ្វើខុសច្បាប់ក៏ដោយ ហើយប្រសិនជាត្រូវធ្វើ "គណៈកម្មការ" ត្រូវធ្វើអនុសាសន៍ចំពោះវិធានការត្រួតពិនិត្យផ្សេងៗដែលសមស្របដើម្បីជាពន្លឺដល់ការវាយតំលៃដូចបានពោលមកនោះ ។

៥. ដោយគិតតាំងពីការសង្កេតផ្សេងៗដែលបានលើកឡើងពីសំណាក់ភាគី ហើយនិងការសង្កេត និងអនុសាសន៍ផ្សេងៗ របស់ "ក្រុមប្រឹក្សា" ដែលគណៈកម្មការបានវាយតំលៃ បញ្ជាក់ច្បាស់លាស់លើទិដ្ឋភាពខាងផ្នែកវិទ្យាសាស្ត្រ និង ដោយយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវផងដែរ ពីកត្តាសមហេតុផលផ្សេងៗដទៃទៀត អាចសំរេចយកតាមសមាជិកភាគច្រើនពីរភាគបី នៃចំនួនសមាជិករបស់ខ្លួនដើម្បីចុះបញ្ជីសារធាតុ ក្នុងតារាងទី១ រឺ តារាងទី២ ។

៦. រាល់សេចក្ដីសំរេច របស់ "គណៈកម្មការ" តាមន័យនៃមាត្រានេះ អគ្គលេខាធិការត្រូវជូនដំណឹងទៅគ្រប់រដ្ឋទាំងអស់ និង អង្គភាពដទៃទៀតដែលជាភាគីនៃអនុសញ្ញានេះ រឺ អង្គភាព ដែលមាននីតិសម្បទា នឹង ក្លាយជាភាគីនៃអនុសញ្ញានេះ ព្រមទាំងត្រូវជូនដំណឹងទៅ "ក្រុមប្រឹក្សា" អោយបានជ្រាប ។ សេចក្ដីសំរេចនេះ នឹងមានអនុភាពអនុវត្តពេញលេញចំពោះភាគីនីមួយៗ ក្រោយ ១៨០ ថ្ងៃ ពីកាលបរិច្ឆេទនៃការជូនដំណឹង ។

៧. ក) សេចក្ដីសំរេចរបស់"គណៈកម្មការ" តាមន័យនៃមាត្រានេះ ត្រូវដាក់ជូនទៅ "ក្រុមប្រឹក្សា" ដើម្បីពិនិត្យសើរើឡើងវិញ បើប្រសិនជា មានភាគីទាមទារសើរើសេចក្ដីសំរេចនេះនៅក្នុងអំឡុងពេល ១៨០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទជូនដំណឹងនៃសេចក្ដីសំរេចរបស់គណៈកម្មការនោះ។ សំណើត្រូវផ្ញើជូនអគ្គលេខាធិការ ដោយមានភ្ជាប់មកជាមួយនូវពត៌មានសមហេតុផលទាំងអស់ដែលជាមូលហេតុនៃសំណើនោះ

ខ) អគ្គលេខាធិការត្រូវជូនលិខិតចំឡងនៃសំណើ និង ពត៌មានដែលពាក់ព័ន្ធទៅ "គណៈកម្មការ" ទៅ"ក្រុមប្រឹក្សា" និង ទៅគ្រប់ភាគីទាំងអស់ ដោយសុំអោយគេទាំងនោះ អធិប្បាយពីការសង្កេតរបស់ ខ្លួនក្នុងរយៈពេល៩០ថ្ងៃ ។ រាល់ការសង្កេតទាំងអស់ដែលបានទទួល ត្រូវជំរាបជូនទៅ "ក្រុមប្រឹក្សា" ដើម្បីពិនិត្យ

គ) "ក្រុមប្រឹក្សា" អាច យល់ព្រម រឺ លុបចោលសេចក្ដីសំរេចរបស់ "គណៈកម្មការ" ។ សេចក្ដីសំរេចរបស់"ក្រុមប្រឹក្សា" ត្រូវបានជំរាបជូនទៅគ្រប់រដ្ឋទាំងអស់ និងទៅអង្គភាពដទៃផ្សេងទៀតដែលជាភាគីនៃអនុសញ្ញានេះ រឺ អង្គភាពដែលមាននីតិសម្បទា នឹងក្លាយជាភាគីនៃអនុសញ្ញានេះ ហើយនិង ជំរាបជូនទៅ "គណៈកម្មការ" និងទៅ "ក្រុមប្រឹក្សា" ។

៨. ក) ដោយគ្មានឡំអៀង ដល់លក្ខណៈទូទៅនៃបទបញ្ញត្តិផ្សេងៗក្នុងកថា ខ័ណ្ឌ១ នៃមាត្រានេះ និងដល់បទបញ្ញត្តិនៃអនុសញ្ញាឆ្នាំ១៩៦១នៃអនុសញ្ញាឆ្នាំ១៩៦១ ដែលបានកែប្រែនិងនៃអនុសញ្ញាឆ្នាំ១៩៧១ ភាគីទាំងឡាយ ត្រូវមានវិធានការផ្សេងៗដែលខ្លួនយល់ឃើញថាសមស្របសំរាប់ត្រួតពិនិត្យ នៅលើទឹកដីរបស់ខ្លួន នូវការធ្វើ និង ការចែកចាយសារធាតុផ្សេងៗដូចមានចុះបញ្ជីក្នុងតារាងទី១ និង តារាងទី២

ខ) ចំពោះគោលបំណងនេះ ភាគីទាំងឡាយអាច :

i) ធ្វើការចាំឃ្លាំមើល លើជនគ្រប់រូប និងលើគ្រប់សហគ្រាសទាំងអស់ ដែលប្រព្រឹត្ត ការធ្វើ និង ការចែកចាយសារធាតុដូចបានពោលមកនោះ ;

ii) តំរូវអោយមានអាជ្ញាប័ណ្ណ គ្រឹះស្ថាន និង ទីកន្លែងដែលមាន ការធ្វើ វិការចែកចាយនោះ

iii) តំរូវអោយម្ចាស់អាជ្ញាប័ណ្ណ មានការអនុញ្ញាតច្បាប់ដើម្បីមានប្រតិបត្តិការផ្សេងៗ ដូចបានរៀបរាប់ខាងលើ

iv) ហាមឃាត់មិនអោយមានការប្រមូលមកនៅក្នុងដៃអ្នកធ្វើ និង អ្នកចែកចាយ នូវបរិមាណសារធាតុ ដូចបានពោលមកនេះលើសពីសេចក្តីត្រូវការសំរាប់ដំណើរការធម្មតាសមហេតុផល របស់ភាគីខ្លួន ព្រមទាំងសេចក្តីត្រូវការរបស់ស្ថានភាពទីផ្សារទេ ។

៩. ទាក់ទងនឹងសារធាតុ ដូចមានចុះបញ្ជីក្នុងតារាងទី១ និង តារាងទី២ ភាគីនីមួយៗត្រូវមានវិធានការផ្សេងៗដូចតទៅនេះ:

ក) ភាគីត្រូវបង្កើត និង ថែរក្សាប្រព័ន្ធចាំឃ្លាំមើលខាងពាណិជ្ជកម្មអន្តរជាតិ នូវសារធាតុផ្សេងៗ ដូចមានចុះបញ្ជីក្នុងតារាងទី១ និង តារាងទី២ ដើម្បីជួយសំរួល ដល់ការរាវរកប្រតិបត្តិការផ្សេងៗដែលជាប់សង្ស័យ ។ ប្រព័ន្ធចាំឃ្លាំមើលទាំងនេះ ត្រូវប្រើដើម្បីអនុវត្តដោយធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទជាមួយ អ្នកធ្វើ អ្នកនាំចូល អ្នកនាំចេញ ឈ្មួញលក់ដុំ និងឈ្មួញលក់រាយ ដែលពួកគេត្រូវជូនពត៌មានដល់អាជ្ញាធរមានសមត្ថកិច្ចផ្សេងៗពីការបញ្ជាទិញ និង ពីប្រតិបត្តិការផ្សេងៗដែលជាប់សង្ស័យ

ខ) ភាគីនីមួយៗត្រូវគ្រោងទុកជាមុន ពីការឃាត់ទុករាល់សារធាតុ ដូចមានចុះបញ្ជីក្នុងតារាងទី១ និង តារាងទី២ បើប្រសិនជាមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា សារធាតុទាំងនោះបំរុងទុកសំរាប់យកទៅប្រើក្នុងការផលិតគ្រឿងញៀនខុសច្បាប់ រឺ សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ

គ) ភាគីនីមួយៗត្រូវជូនពត៌មានយ៉ាងឆាប់បំផុតទៅអាជ្ញាធរ និង អង្គភាពមានសមត្ថកិច្ចផ្សេងៗនៃភាគីសាមីទាំងឡាយបើប្រសិនជាមានមូលហេតុជឿថា សារធាតុមួយដែលមានចុះបញ្ជីក្នុងតារាងទី១ រឺ តារាង ទី២ ត្រូវបាននាំចូល នាំចេញ រឺ មានទិសដៅឆ្លងកាត់សំរាប់ការផលិតគ្រឿងញៀនខុសច្បាប់ រឺសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ជាអាទិ៍ ត្រូវផ្តល់ពត៌មានដល់អាជ្ញាធរ និងអង្គភាពទាំងនោះ ពីរបៀបទូទាត់ប្រាក់ ព្រមទាំងធាតុសំខាន់ដទៃទៀតទាំងអស់ដែលនាំអោយភាគីមានជំនឿនោះ

ឃ) ភាគីត្រូវតំរូវអោយការផ្ញើដែលជាកម្មវត្ថុនៃការនាំចូល និងការនាំចេញ ត្រូវតែមានដាក់ម៉ាកអោយបានត្រឹមត្រូវនិងជូនភ្ជាប់នូវឯកសារចាំបាច់ផ្សេងៗអោយបានត្រឹមត្រូវ ។ ឯកសារ

ពាណិជ្ជកម្មផ្សេងៗ ដូចជាវិក្កយប័ត្រ និវេទនីប័ណ្ណ ឯកសារគយ ឯកសារដឹកជញ្ជូន និងឯកសារ របស់ផ្ញើត្រូវតែមានដាក់ឈ្មោះសារធាតុដែលជាកម្មវត្ថុនៃការនាំចូល រឺ ការនាំចេញ ដូចឈ្មោះ ដែលមានចែង នៅក្នុងតារាងទី១ រឺ តារាងទី២ និងមានដាក់បរិមាណនាំចូល រឺ នាំចេញ ព្រមទាំង ឈ្មោះ និងអាសយដ្ឋាន នៃអ្នកនាំចេញ អ្នកនាំចូល ហើយកាលបើស្គាល់ គឺត្រូវដាក់ឈ្មោះ និងអាសយដ្ឋាននៃអ្នកទទួលផងដែរ

ង) ភាគីត្រូវធ្វើយ៉ាងណាអោយ ឯកសារដូចមានចែងនៅក្នុងវគ្គ ឃ នៃកថាខ័ណ្ឌនេះត្រូវរក្សា ទុកអោយបានសំរាប់រយៈពេលយ៉ាងតិច២ឆ្នាំ ហើយត្រូវមានទុកបំរុង សំរាប់អាជ្ញាធរមាន សមត្ថកិច្ចផ្សេងៗធ្វើការពិនិត្យផងដែរ ។

១០. ក) បន្ថែមទៅលើបទបញ្ញត្តិនៃកថាខ័ណ្ឌ៩ និង ដោយមានសំណើទៅអគ្គលេខាធិការនៃភាគី ទទួលសំណើ ភាគីនីមួយៗដែលទឹកដីរបស់ខ្លួនមានសារធាតុមួយដែលចុះបញ្ជីក្នុង តារាងទី១ ត្រូវបាននាំចេញត្រូវរ៉ាប់រងថាមុននឹងនាំចេញ ពតិមានបន្ទាប់នេះ អាជ្ញាធរមានសមត្ថកិច្ចរបស់ ខ្លួនត្រូវតែផ្តល់ទៅឱ្យ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចូល :

i) ឈ្មោះ និង អាស័យដ្ឋានរបស់អ្នកនាំចេញ និងរបស់អ្នកនាំចូល ហើយកាលបើស្គាល់ ឈ្មោះ និង អាសយដ្ឋានរបស់អ្នកទទួល

ii) ឈ្មោះសារធាតុដែលមាននៅក្នុងតារាងទី១

iii) បរិមាណសារធាតុដែលត្រូវនាំចេញ

iv) ចំណុចនាំចូលដែលគ្រោងទុក និង កាលបរិច្ឆេទនៃរបស់ផ្ញើដែលគ្រោងទុក

v) ពតិមានដទៃទៀតទាំងអស់ដែលបានព្រមព្រៀងគ្នាទៅវិញទៅមក រវាងភាគី ផ្សេងៗ។

ខ) ភាគីនីមួយៗ អាចអនុម័តយកវិធានការត្រួតពិនិត្យផ្សេងៗយ៉ាងតឹងរឹង ឬ យ៉ាងខ្លាំង ជាង វិធានការដែលគ្រោងទុកនៅក្នុងកថាខ័ណ្ឌនេះ បើប្រសិនជាភាគីនោះយល់ថាវិធានការនោះ គួរតែ ធ្វើ រឺក៏ចាំបាច់ត្រូវធ្វើ ។

១១. កាលបើភាគីមួយ ផ្តល់ពតិមានផ្សេងៗ ទៅឱ្យភាគីមួយទៀតដោយអនុលោមតាម កថាខ័ណ្ឌ៩ និង ១០ នៃមាត្រានេះ ភាគីនោះអាចតំរូវអោយភាគីទទួលពតិមានការពារនូវលក្ខណៈអាថិកំបាំង នៃរាល់ ការសំងាត់ផ្នែកសេដ្ឋកិច្ច ឧស្សាហកម្ម ពាណិជ្ជកម្ម រឺ វិជ្ជាជីវៈ រឺរបៀបធ្វើពាណិជ្ជកម្ម ដែលពតិមាន ទាំងនោះ អាចមាន ។

១២. ជារៀងរាល់ឆ្នាំ ភាគីនីមួយៗត្រូវផ្តល់នូវពត៌មានទៅឱ្យ "ក្រុមប្រឹក្សា" តាមទំរង់ និង តាមបែបបទដែលបានកំណត់ពី "ក្រុមប្រឹក្សា" និងដោយប្រើរូបមន្តដែល "ក្រុមប្រឹក្សា" ផ្តល់អោយទៅ ភាគី ពី :

ក) ទំហំបរិមាណនៃសារធាតុ ដែលមានចុះបញ្ជីនៅក្នុងតារាងទី១ និង តារាងទី២ ដែលបានឃាត់ទុក និងបើប្រសិនជាភាគីនោះស្គាល់ សូមប្រាប់ពីដើមកំណើតរបស់សារធាតុទាំងនោះ

ខ) សារធាតុផ្សេងទៀត ដែលគ្មានចុះបញ្ជីក្នុងតារាងទី១ រឺ តារាងទី២ ប៉ុន្តែជាសារធាតុ ដែលត្រូវបានគេធ្វើអត្តសញ្ញាណឃើញថា បានយកទៅប្រើក្នុងការផលិតគ្រឿងញៀនខុសច្បាប់ រឺសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ហើយដែលភាគីនោះពិចារណាទៅឃើញថាសំខាន់គ្រប់គ្រាន់ដើម្បីទាក់ទាញការប្រុងប្រយ័ត្នដល់ "ក្រុមប្រឹក្សា"

គ) វិធីសាស្ត្រនៃការផលិត និង បង្វែរខុសច្បាប់

១៣. ជារៀងរាល់ឆ្នាំ "ក្រុមប្រឹក្សា" ត្រូវធ្វើរបាយការណ៍ ទៅឱ្យ "គណៈកម្មការ" ស្តីពីការអនុវត្តមាត្រានេះ ហើយ "គណៈកម្មការ" ត្រូវពិនិត្យដោយទៀងទាត់ពេលវេលា ថាតើតារាងទី១ និង តារាងទី២ត្រឹមត្រូវ និង សមហេតុផលឬទេ ។

១៤. បទបញ្ញត្តិនៃមាត្រានេះ មិនអាចយកមកអនុវត្តចំពោះការផ្សំបែបឱសថសាស្ត្រទាំងការផ្សំដទៃទៀត ដែលមានសារធាតុចុះក្នុងតារាងទី ១ រឺតារាងទី២ហើយដែលសមាសធាតុតាមរបៀបមួយដែលសារធាតុ ដូចបានពោលនោះមិនអាចប្រើបានយ៉ាងងាយស្រួល រឺមិនអាចចំរាញ់ទាញដកយកមកវិញបានតាមរយៈមធ្យោបាយងាយអនុវត្តនោះទេ ។

## មាត្រា ១៣ : សំភារៈ និង បរិក្ខារ

ភាគីត្រូវមានវិធានការផ្សេងៗ ដែលខ្លួនយល់ឃើញថាសមស្របដើម្បីបង្ការកុំឱ្យមានការធ្វើពាណិជ្ជកម្ម និង ការបំបែរសំភារៈនិងបរិក្ខារផ្សេងៗ សំរាប់យកទៅផលិត រឺធ្វើខុសច្បាប់នូវគ្រឿងញៀន និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទហើយភាគីទាំងនោះត្រូវតែធ្វើសហប្រតិបត្តិការជាមួយគ្នា ដើម្បីគោលដៅនេះ។

## មាត្រា ១៤ : វិធានការលុបបំបាត់ការដាំដុះខុសច្បាប់នូវរុក្ខជាតិដែលចំរាញ់ចេញជាគ្រឿងញៀននិងការលុបបំបាត់តំរូវការខុសច្បាប់នូវគ្រឿងញៀន និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ

១. ដោយអនុលោមដាច់ខាតតាមបទបញ្ញត្តិ នៃអនុសញ្ញាឆ្នាំ១៩៦១ និង អនុសញ្ញាឆ្នាំ១៩៦១ ដែលបានកែប្រែ ព្រមទាំងអនុសញ្ញាឆ្នាំ១៩៧១ វិធានការទាំងឡាយ ដែលភាគីប្រកាន់យកតាមន័យ នៃអនុសញ្ញា នេះនឹងមិនត្រូវតឹងរឹង តិចជាងបទបញ្ញត្តិដែលអនុវត្ត សំរាប់លុបបំបាត់ ការដាំដុះខុសច្បាប់ នូវរុក្ខជាតិដែលមានជាតិគ្រឿងញៀន និង មានជាតិសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង មិនត្រូវតឹងរឹងអោយតិចជាងបទបញ្ញត្តិដែលអនុវត្តសំរាប់លុបបំបាត់ចរាចរការខុសច្បាប់គ្រឿងញៀននិង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទនោះទេ ។

២. ភាគីនីមួយៗត្រូវប្រកាន់យក វិធានការសមស្របនៅលើទឹកដីរបស់ខ្លួន ដើម្បីហាមឃាត់កុំឱ្យមានការដាំដុះខុសច្បាប់ នូវរុក្ខជាតិដែលមានជាតិគ្រឿងញៀន រឺមានសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដូចជា ដើមអាភៀន ដើមកូកា និង រុក្ខជាតិកញ្ឆា ហើយនិងបំផ្លាញចោលរុក្ខជាតិ ដែលដាំខុសច្បាប់ នៅលើទឹកដីរបស់ខ្លួន ។ វិធានការដែលបានអនុម័ត ត្រូវតែគោរពដល់សិទ្ធិសំខាន់ៗរបស់មនុស្ស និង ត្រូវគិតអោយបាន ត្រឹមត្រូវពីការប្រើស្របច្បាប់តាមប្រពៃណី កាលបើការប្រើប្រាស់បែបនេះត្រូវបានបញ្ជាក់តាម ប្រវត្តិសាស្ត្រ ព្រមទាំងការការពារបរិស្ថានផងដែរ ។

៣. ក) ភាគីទាំងឡាយអាចសហប្រតិបត្តិការគ្នា ដើម្បីបង្កើនការខិតខំប្រឹងប្រែងអោយមានប្រសិទ្ធភាព ជាងមុនសំដៅលុបបំបាត់ការដាំដុះខុសច្បាប់ ។ កិច្ចសហប្រតិបត្តិការនេះអាចជាអាទិ៍បើប្រសិនជាត្រូវធ្វើ ត្រូវជាបង្អែកសំរាប់ការអភិវឌ្ឍន៍ជនបទបញ្ចូលគ្នា ដោយនាំទៅរកការដាំដុះជំនួសដោយមានលក្ខណៈសេដ្ឋកិច្ច អាចឋិតថេរបាន ។ មុននឹងអនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទបែបនេះ គេត្រូវតែគិតពីកត្តាផ្សេងៗ ដូចជាលទ្ធភាពនៅទីផ្សារ ធនធានបំរុងទុក និងស្ថានភាពសង្គម-សេដ្ឋកិច្ច ។ ភាគីទាំងឡាយ អាចព្រមព្រៀងគ្នាជ្រើសរើសយកវិធានការសមស្របដទៃទៀត ខាងកិច្ចសហប្រតិបត្តិការ

ខ) ភាគីទាំងឡាយ ក៏ត្រូវជួយសំរួលការផ្លាស់ប្តូរ ពត៌មានខាងវិទ្យាសាស្ត្រ និង ខាងបច្ចេកទេស និងការប្រតិបត្តិការងារស្រាវជ្រាវ ស្តីពីការលុបបំបាត់ការដាំដុះខុសច្បាប់ផងដែរ

គ) កាលណា ភាគីមានព្រំដែនរួមគ្នា ភាគីទាំងនោះត្រូវខិតខំប្រឹងប្រែង ធ្វើសហប្រតិបត្តិការនៅក្នុងកម្មវិធីលុបបំបាត់ ការដាំដុះខុសច្បាប់ ក្នុងតំបន់តាមបណ្តោយព្រំដែនរៀងៗខ្លួន ។

៤. ភាគីត្រូវអនុម័តវិធានការសមស្របផ្សេងៗ សំដៅលុបបំបាត់ រឺកាត់បន្ថយតំរូវការគ្រឿងញៀនខុសច្បាប់ និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ក្នុងចេតនា កាត់បន្ថយការឈឺចាប់របស់មនុស្សជាតិ និង លុបបំបាត់ ការលើកទឹកចិត្តខាងហិរញ្ញវត្ថុដែលបានមកពីការចរាចរខុសច្បាប់ ។ វិធានការទាំង នេះ

អាចត្រូវបានបង្កើតជាអាទិ៍ ដោយផ្អែកលើអនុសាសន៍របស់អង្គការសហប្រជាជាតិ របស់ស្ថាប័នឯកទេសនៃអង្គការសហប្រជាជាតិ ដូចជាអង្គការសុខភាពពិភពលោក និង អង្គការមានសមត្ថកិច្ចអន្តរជាតិផ្សេងទៀត និង ដោយផ្អែកលើគោលសំខាន់ៗខាងពហុវិធានការ ដែលបានអនុម័តដោយសន្និសីទអន្តរជាតិស្តីពីការប្រើបំពាន និងការចរាចរគ្រឿងឪសថខុសច្បាប់ដែលបានប្រព្រឹត្តទៅនាឆ្នាំ ១៩៨៧ ក្នុងករណីដែលគោលសំខាន់ៗ ខាងពហុវិធានការពេញលេញនេះជាប់ទាក់ទងនឹងការខិតខំប្រឹងប្រែងរបស់អង្គការរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាល និង ជាប់ទាក់ទងនឹង គំនិត ផ្តួចផ្តើមជាឯកជន នៅក្នុងវិស័យបង្ការការពារ ព្យាបាល និងធ្វើនីតិសម្បទាឡើងវិញ។ ភាគីអាចធ្វើអោយមានកិច្ចព្រមព្រៀង រឺ កិច្ចសំរុះសំរួលទ្វេភាគី រឺពហុភាគីផ្សេងៗ សំដៅលុបបំបាត់ រឺ កាត់បន្ថយ តំរូវការខុសច្បាប់គ្រឿងញៀន និង សារធាតុប៉ះពាល់ ប្រព័ន្ធសរសៃប្រសាទ ។

៥. ភាគីទាំងឡាយក៏អាចចាត់ វិធានការចាំបាច់ផ្សេងៗដើម្បីបំផ្លាញចោលឱ្យបានឆាប់រហ័ស រឺប្រើប្រាស់ឱ្យបានស្របច្បាប់នូវគ្រឿងញៀន សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង សារធាតុដូចមានចុះបញ្ជីក្នុងតារាងទី១ និង តារាងទី២ ដែលបានឃាត់ទុក រឺ រឹបអូស ហើយនិងចាត់វិធានការចាំបាច់ផ្សេងៗដើម្បីអោយបរិមាណចាំបាច់នៃសារធាតុដោយមានបញ្ជាក់ត្រឹមត្រូវ ទទួលយកទុកជាភស្តុតាងបាន ។

## មាត្រា ១៥ : ឈ្មួញដឹកជញ្ជូន

ភាគីទាំងឡាយ ត្រូវមានវិធានការផ្សេងៗសមស្រប ក្នុងចេតនាធានាថា មធ្យោបាយដឹកជញ្ជូនដែលយកមកប្រើធ្វើអាជីវកម្មដោយឈ្មួញដឹកជញ្ជូន មិនត្រូវបានយកទៅប្រើ ក្នុងការប្រព្រឹត្តបទល្មើសដែលមានចែង ដោយអនុលោមតាមកថាខ័ណ្ឌ១នៃមាត្រា៣ទេ។ វិធានការទាំងឡាយនោះអាចមានរួមបញ្ចូលទាំងការ ធ្វើអោយមានកិច្ចសំរុះសំរួលពិសេសៗ ជាមួយនឹងឈ្មួញដឹកជញ្ជូនទាំងនោះផង ។

២. ភាគីនីមួយៗ ត្រូវតំរូវឱ្យឈ្មួញដឹកជញ្ជូនប្រកាន់ខ្ជាប់នូវការប្រុងប្រយ័ត្នដ៏សមហេតុសមផលដើម្បីហាមឃាត់កុំអោយយកមធ្យោបាយដឹកជញ្ជូនរបស់ខ្លួន ទៅប្រើក្នុងការប្រព្រឹត្តបទល្មើសដែលមានចែងដោយ អនុលោមតាម កថាខ័ណ្ឌ១ នៃមាត្រា៣ ។ ការប្រុងប្រយ័ត្នទាំងឡាយនោះអាចមាន ជាអាទិ៍ :

ក) បើប្រសិនជា ឈ្មួញដឹកជញ្ជូន មានគ្រឹះស្ថានមេរបស់ខ្លួននៅក្នុងទឹកដីរបស់ភាគីនោះ :

i) ត្រូវបណ្តុះបណ្តាលបុគ្គលិកសំរាប់ធ្វើអត្តសញ្ញាណការថ្មី រឺបុគ្គល ដែលជាប់សង្ស័យ

ii) ត្រូវលើកកំពស់សេចក្តីសុចរិតរបស់បុគ្គលិក

ខ) បើប្រសិនជា ឈ្មួញដឹកជញ្ជូន ប្រតិបត្តិការនៅក្នុងទឹកដីរបស់ភាគីនោះ :

i) ត្រូវតំកល់ទុកនិវេទន៍ជាមុន រាល់ពេលដែលកិច្ចការនោះអាចមាន

ii) ចំពោះកុងទែន័រ ត្រូវប្រើផ្ទាំងក្រណាត់បោះត្រាមិនអាចក្លែងបានហើយដែលអាចត្រួតពិនិត្យដោយលក្ខណៈឯកត្តជនបាន

iii) ត្រូវជូនពត៌មានដល់អាជ្ញាធរមានសមត្ថកិច្ច ក្នុងរយៈពេលដ៏សមស្របបំផុតចំពោះរាល់ស្ថានភាពសង្ស័យដែលអាចជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើសដែលមានចែង ដោយអនុលោមតាមកថាខ័ណ្ឌ ១ នៃមាត្រា៣ ។

៣. នៅត្រង់ចំណុចចូល និងចេញ និងនៅក្នុងតំបន់ត្រួតពិនិត្យគយភាគីនីមួយៗ ត្រូវរិះរកយ៉ាងណាវាំបំរងអោយឈ្មួញដឹកជញ្ជូន និង អាជ្ញាធរមានសមត្ថកិច្ចសហការគ្នាក្នុងចេតនាហាមឃាត់ការចូលដោយគ្មានការអនុញ្ញាត ចំពោះមធ្យោបាយដឹកជញ្ជូន និង ទំនិញផ្ទុក និង ក្នុងចេតនាអនុវត្ត វិធានការសន្តិសុខសមស្របនានា ។

## មាត្រា ១៦ : ឯកសារពាណិជ្ជកម្ម និង ការដាក់ម៉ាកនាំចេញ

១. ភាគីនីមួយៗ ត្រូវតំរូវឱ្យរបស់ផ្ញើដែលស្របច្បាប់ទាំងឡាយ ខាងគ្រឿងញៀននិងសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទដែលត្រូវនាំចេញ ត្រូវមានភ្ជាប់នូវឯកសារចាំបាច់ផ្សេងៗ មកជាមួយ ។ លើសពីនេះទៅទៀត ចំពោះតំរូវការសំរាប់ឯកសារដែលមានចែងនៅក្នុងមាត្រា ៣១ នៃ អនុសញ្ញាឆ្នាំ ១៩៦១ ក្នុងមាត្រា ៣១ នៃអនុសញ្ញាឆ្នាំ ១៩៦១ ដែលបានកែប្រែ និង ក្នុងមាត្រា ១២ នៃអនុសញ្ញាឆ្នាំ ១៩៧១ នោះចំពោះឯកសារពាណិជ្ជកម្មផ្សេងៗដូចជា វិក្កយប័ត្រ និវេទន៍ ឯកសារគយ ឯកសារដឹកជញ្ជូន និង ឯកសារនៃរបស់ផ្ញើដទៃទៀត ត្រូវតែមានដាក់ឈ្មោះគ្រឿងញៀន និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទដែលជាកម្មវត្ថុនៃការនាំចេញ ដូចដែលមាននៅក្នុងតារាង សមហេតុផលផ្សេងៗ នៃអនុសញ្ញាឆ្នាំ ១៩៦១ នៃអនុសញ្ញាឆ្នាំ ១៩៦១ ដែលបានកែប្រែ និង នៃអនុសញ្ញាឆ្នាំ១៩៧១ហើយត្រូវតែមានដាក់បរិមាណនាំចេញ ព្រមទាំងឈ្មោះ និង អាស័យដ្ឋានរបស់ អ្នកនាំចេញ អ្នកនាំចូល និង កាលបើស្គាល់ត្រូវមានដាក់ឈ្មោះ អាស័យដ្ឋាននៃអ្នកទទួលទំនិញផង ។

២. ភាគីនីមួយៗ ត្រូវតំរូវឱ្យការផ្ញើគ្រឿងញៀន និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលត្រូវនាំចេញ មិនត្រូវដាក់ម៉ាកអោយខុសទេ ។

## មាត្រា១៧ : ការចរាចរខុសច្បាប់តាមសមុទ្រ

១. ភាគីទាំងឡាយ ត្រូវសហប្រត្តិបត្តិការគ្នាក្នុងគ្រប់ករណីដែលមានចេតនាបញ្ឈប់ការចរាចរខុស

ច្បាប់តាមផ្លូវសមុទ្រ ដោយអនុលោមតាម នីតិអន្តរជាតិស្តីពីសមុទ្រ ។

២. ដោយមានមូលហេតុ សមហេតុសមផលសង្ស័យថា នាវាមួយដែលមានដោតទង់ជាតិរបស់ភាគីខ្លួន រឺ មិនបានដោតទង់ណាមួយសោះ រឺគ្មានពាក់ផ្លាកសញ្ញាចុះបញ្ជីណាមួយធ្វើចរាចរខុសច្បាប់នោះភាគីអាចស្នើសុំអោយភាគីដទៃទៀតជួយទំនុកបំរុងខ្លួន អោយបញ្ឈប់ការប្រើប្រាស់នេះ ។ ភាគីដែលស្នើសុំត្រូវផ្តល់ជំនួយទំនុកបំរុងនេះ ទៅតាមកំរិតមធ្យោបាយផ្សេងៗដែលភាគីខ្លួនមាន ។

៣. ភាគីមួយ ដោយមានមូលហេតុសមហេតុសមផលសង្ស័យថា នាវាមួយមានសេរីភាពធ្វើនាវាចរណ៍ ដោយអនុលោមតាមនីតិអន្តរជាតិហើយមានដោតទង់ជាតិ រឺមានពាក់សញ្ញាចុះបញ្ជីរបស់ភាគីម្ខាងទៀត ធ្វើចរាចរខុសច្បាប់ អាចធ្វើលិខិតជូនដំណឹងទៅរដ្ឋនៃទង់ជាតិនោះ ទាមទារសុំឱ្យបញ្ជាក់ពីការចុះបញ្ជី ហើយ បើប្រសិនជាការចុះបញ្ជីមានពិតប្រាកដមែន ភាគីត្រូវទាមទារសុំអោយពីរដ្ឋនោះមានវិធានការសមស្រប ចំពោះនាវានោះ ។

៤. ដោយអនុលោមតាមបទបញ្ញត្តិនៃកថាខ័ណ្ឌ ៣ រឺតាមសន្ធិសញ្ញាផ្សេងៗ ដែលមានជាធរមានរវាង ភាគី រឺក៏តាមកិច្ចព្រមព្រៀង រឺ កិច្ចសំរុះសំរួលផ្សេងទៀត ដែលភាគីទាំងនោះបានធ្វើឱ្យមានជាមួយគ្នា រដ្ឋម្ចាស់ទង់ជាតិអាចអនុញ្ញាតជាអាទិ៍ឱ្យរដ្ឋដាក់សំណើ :

ក) ឡើងនាវា

ខ) ឆែកឆេរនាវា

គ) មានវិធានការសមស្របចំពោះនាវា ចំពោះបុគ្គលនៅលើនាវានោះ និងចំពោះទំនិញដឹកជញ្ជូន បើប្រសិនជារកឃើញមានភស្តុតាងចូលរួមក្នុងចរាចរខុសច្បាប់ ។

៥. កាលណាវិធានការមួយត្រូវចាត់ដោយសារអនុវត្តមាត្រានេះចាំបាច់ ភាគីសាមីត្រូវគិតឱ្យបានត្រឹមត្រូវពីភាពមិនត្រូវឱ្យប៉ះពាល់ដល់សន្តិសុខនៃជីវិតរស់នៅក្នុងសមុទ្រ និង សន្តិសុខនៃនាវាព្រមទាំង ទំនិញដឹកជញ្ជូនរបស់នាវា ហើយនិងមិនត្រូវអោយមានការលំអៀងដល់ផលប្រយោជន៍ពាណិជ្ជកម្ម និង គតិយុត្តនៃ រដ្ឋម្ចាស់ទង់ជាតិ រឺ ដល់រាល់រដ្ឋសាមីដទៃទៀតទេ។

៦. ក្នុងករណីសមិតភាពជាមួយនឹងកាតព្វកិច្ចរបស់រដ្ឋខ្លួនក្នុងនាមកថាខ័ណ្ឌ១ នៃមាត្រានេះរដ្ឋម្ចាស់ ទង់ជាតិ អាចអនុញ្ញាតដោយមានល័ក្ខខ័ណ្ឌដែលត្រូវមានការព្រមព្រៀងគ្នារវាងរដ្ឋនៃទង់ជាតិ និងរដ្ឋដាក់ សំណើ ជាអាទិ៍ ទាក់ទងនឹងការទទួលខុសត្រូវ ។

៧. សំរាប់គោលបំណងនៃកថាខ័ណ្ឌ៣ និង ៤ នៃមាត្រានេះភាគីនីមួយៗត្រូវរួសរាន់ឆ្លើយតបទៅនឹងសំណើនីមួយៗរបស់ភាគីម្ខាងទៀតមកលើខ្លួន ក្នុងចេតនាបញ្ជាក់ថា នាវាមានដោតទង់ជាតិរបស់ខ្លួននោះត្រូវបានទទួលការអនុញ្ញាតមែន និងត្រូវរួសរាន់ឆ្លើយតប ចំពោះសំណើសុំការអនុញ្ញាត ទាំងឡាយដែលបានស្នើដោយអនុវត្តតាមកថាខ័ណ្ឌ៣ ។ នៅពេលដែលរដ្ឋបានក្លាយជាភាគីនៃអនុសញ្ញានេះរដ្ឋនីមួយៗនោះត្រូវចាត់តាំងអាជ្ញាធរមួយ រឺ ប្រសិនជាត្រូវធ្វើអាជ្ញាធរច្រើនដែលមាននីតិសម្បទាសំរាប់ទទួលនិងឆ្លើយតបនឹងសំណើបែបនោះ។ នៅក្នុងរយៈពេលមួយខែបន្ទាប់ពីការចាត់តាំងនោះអគ្គលេខាធិការ ត្រូវធ្វើលិខិតជូនដំណឹងទៅគ្រប់ភាគីដទៃទៀតទាំងអស់ពីអាជ្ញាធរដែលបានចាត់តាំងពីភាគីនីមួយៗ នោះ ។

៨. ភាគីដែលបានប្រកាន់យកវិធានការណាមួយដូចបានគ្រោងទុកក្នុងមាត្រានេះ ត្រូវរួសរាន់ផ្តល់ពតិមានទៅឱ្យរដ្ឋម្ចាស់ទង់ជាតិដែលពាក់ព័ន្ធនោះ ពីលទ្ធផលនៃវិធានការមួយនោះ ។

៩. ភាគីទាំងឡាយនឹងយកមកពិនិត្យធ្វើអោយមានកិច្ចព្រមព្រៀង រឺកិច្ចសំរុះសំរួលជាទ្វេភាគី រឺតំបន់ក្នុងចេតនាផ្តល់ផលអនុវត្តដល់បទបញ្ញត្តិនៃមាត្រានេះ រឺ ពង្រឹងប្រសិទ្ធិភាពបទបញ្ញត្តិទាំងនេះ។

១០. វិធានការនានាដែលមានពេលអនុវត្តកថាខ័ណ្ឌ៤ ត្រូវអនុវត្តតែលើនាវាចំបាំង រឺ យន្តហោះយោធា រឺក៏នាវា រឺ យន្តហោះដទៃទៀត ដែលមាននីតិសម្បទាត្រឹមត្រូវបែបនេះមានដាក់ម៉ាកខាងក្រៅ អាចមើលឃើញ និង អាចធ្វើអត្តសញ្ញាណបានថាជាសេវារបស់រដ្ឋ ។

១១. រាល់វិធានការដែលប្រើដោយ អនុលោមតាមមាត្រានេះ ត្រូវគិតអោយបានត្រឹមត្រូវស្របតាមនីតិអន្តរជាតិសមុទ្រ ពីភាពចាំបាច់មិនរំលោភលើសិទ្ធិ និង កាតព្វកិច្ច និង ការអនុវត្តសមត្ថកិច្ចនៃរដ្ឋនានាដែលនៅជាប់តាមឆ្នេរសមុទ្រ ព្រមទាំងមិនអោយប៉ះពាល់ដល់សិទ្ធិ កាតព្វកិច្ច រឺ សមត្ថកិច្ចទាំងនោះផងដែរ ។

## មាត្រា១៨ : តំបន់រួចពន្ធ និង កំពង់ផែរួចពន្ធ

១. ដើម្បីបញ្ឈប់ការចរាចរគ្រឿងញៀន ខុសច្បាប់ និង សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងសារធាតុដូចមានចុះបញ្ជីក្នុងតារាងទី១ និង តារាងទី២ ក្នុងតំបន់រួចពន្ធ និង កំពង់ផែរួចពន្ធភាគីទាំងឡាយត្រូវ អនុវត្តនូវវិធានការនានា ដែលប្រិតប្រៀបមិនអោយតិចជាងវិធានការដែលភាគីទាំងនោះអនុវត្តក្នុងផ្នែកដទៃទៀតនៃទឹកដីរបស់ខ្លួននោះទេ ។

២. ភាគីទាំងឡាយត្រូវខិតខំ :

ក) ចាំឃ្លាំមើលចលនាទំនិញ និងជនទាំងឡាយនៅក្នុងតំបន់រួចពន្ធ និង កំពង់ផែរួចពន្ធ ហើយសំរាប់គោលបំណងនេះ ភាគីទាំងនេះត្រូវផ្តល់នីតិសម្បទាដល់អាជ្ញាធរមានសមត្ថកិច្ចអោយធ្វើនីតិវិធីសំរាប់ទៅពិនិត្យទំនិញផ្ទុក និងនាវាចូល និងចេញផ្សេងៗ មានរួមទាំងនាវាកំសាន្ត និង នាវានេសាទក៏ដូចជា យន្តហោះ និង យានទាំងឡាយដែរ ហើយ កាលបើមានអោយឆែកឆេរសមាជិកក្រុមយានិកនិងអ្នកដំណើរព្រមទាំង អីវ៉ាន់របស់គេទាំងនោះ

ខ) បង្កើត និង រក្សាប្រព័ន្ធមួយទុក ដែលអាចរកឃើញ របស់ផ្ញើដែលសង្ស័យបង្កប់គ្រឿងញៀនសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដូចមានចុះបញ្ជីក្នុងតារាងទី១ និង តារាងទី២ ដែលចូលមកក្នុងតំបន់រួចពន្ធ និង កំពង់ផែរួចពន្ធ រឺដែលចេញពីតំបន់ និងកំពង់ផែនោះ

គ) បង្កើត និង រក្សារប្រព័ន្ធជាច្រើនទុកចាំឃ្លាំមើលក្នុងអាង និង ឃ្លាំងនានាតាមកំពង់ផែក៏ដូចជាតាមអាកាសយានដ្ឋាន និង តាមប៉ុស្តិ៍ទល់ដែនផ្សេងៗក្នុងតំបន់រួចពន្ធ និងកំពង់ផែរួចពន្ធ ។

## មាត្រា១៩ : ការប្រើប្រាស់សេវាប្រៃសណីយ៍

១. ដោយប្រតិបត្តិតាមកាតព្វកិច្ចរបស់ខ្លួន ដែលមានក្នុងអនុសញ្ញានៃសហភាពប្រៃសណីយ៍សកល និង អនុលោមទៅតាមគោលការណ៍គ្រឹះ នៃប្រព័ន្ធគតិយុត្តផ្ទៃក្នុងប្រទេសរបស់ខ្លួន ភាគីទាំងឡាយត្រូវមានវិធានការផ្សេងៗ ដើម្បីបញ្ឈប់ការយកសេវាប្រៃសណីយ៍ ប្រើក្នុងគោលបំណងចរាចរខុសច្បាប់ ហើយត្រូវសហប្រតិបត្តិការរវាងគ្នា ចំពោះគោលបំណងនេះ ។

២. វិធានការទាំងឡាយ ដូចមានចែងនៅក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះត្រូវ មានជាអាទិ៍ :

ក) កិច្ចសហការមួយដើម្បីទប់ស្កាត់ និង ដើម្បីបង្ក្រាបការយកអង្គភាពប្រៃសណីយ៍ប្រើប្រាស់ក្នុងគោលដៅប្រព្រឹត្តចរាចរខុសច្បាប់

ខ) ការអនុម័តយក និង ការប្រើនូវបច្ចេកទេសស៊ើបអង្កេត និងត្រួតពិនិត្យតាមរយៈអង្គភាពរាវរក និងបង្ក្រាប ដែលមាននីតិសម្បទាបែបនេះ អាចជួយអោយរកឃើញអាថិកំបាំង ក្នុងការផ្ញើតាមប្រៃសណីយ៍នូវរបស់ផ្ញើខុសច្បាប់នូវគ្រឿងញៀនសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងសារធាតុមានចុះបញ្ជីក្នុងតារាងទី១ និងតារាងទី២

គ) វិធានការច្បាប់នានា ដែលតំរូវអោយប្រើមធ្យោបាយសមស្របដើម្បីប្រមូលយកភ័ស្តុតាងចាំបាច់ ផ្សេងៗសំរាប់ធ្វើការចោទប្រកាន់ខាងតុលាការ ។

**មាត្រា២០ : ពត៌មានត្រូវផ្តល់ពីសំណាក់ភាគី**

១. ភាគីទាំងឡាយ ត្រូវផ្តល់ជូនទៅ "គណៈកម្មការ" តាមរយៈអគ្គលេខាធិការនូវពត៌មាននានាពីការអនុវត្តអនុសញ្ញានេះ នៅក្នុងទឹកដីរបស់ភាគីខ្លួន និង ជាពិសេស :

ក) អត្ថបទច្បាប់ និង បទបញ្ញាផ្សេងៗ ដែលបានប្រកាសប្រើ សំរាប់អនុវត្តអនុសញ្ញានេះ

ខ) សេចក្តីលំអិត ពីកិច្ចការចរាចរខុសច្បាប់ ដែលទាក់ទងនឹងសមត្ថកិច្ចរបស់ខ្លួនហើយដែលភាគីទាំងនោះយល់ថាសំខាន់ពីព្រោះកិច្ចការទាំងនោះពាក់ព័ន្ធទៅនឹងនិន្នាការថ្មីៗ ដោយមានបញ្ជាក់ពីបរិមាណដែលប្រព្រឹត្ត ពីប្រភពដែលនាំឱ្យមានសារធាតុទាំងនោះ រឺពីប្រភពដែលនាំអោយមានវិធីប្រើពីសំណាក់ជនដែលប្រព្រឹត្តការចរាចរខុសច្បាប់ ។

២. ភាគីទាំងឡាយ ត្រូវផ្តល់ពត៌មានទាំងនោះតាមរបៀប និងតាមកាលបរិច្ឆេទដែល "គណៈកម្មការ" កំណត់អោយ ។

**មាត្រា២១ : មុខងាររបស់គណៈកម្មការ**

"គណៈកម្មការ" ដែលត្រូវបានផ្តល់សិទ្ធិពិចារណា រាល់បញ្ហាដែលមានទាក់ទងទៅនឹងគោលបំណងនៃអនុសញ្ញានេះ និង ជាពិសេស :

ក) ផ្អែកលើពត៌មាន ដែលភាគីទាំងឡាយបានជំរាបជូនដោយអនុលោមតាមមាត្រា ២០ "គណៈកម្មការ" ត្រូវតាមដានការយកទៅអនុវត្តអនុសញ្ញានេះ

ខ) "គណៈកម្មការ" អាចផ្តល់យោបល់ និងអនុសាសន៍ដែលមានលក្ខណៈទូទៅផ្សេងៗដោយផ្អែកលើការពិនិត្យពត៌មាន ដែលបានទទួលពីភាគីនានា

គ) "គណៈកម្មការ" អាចទាញអារម្មណ៍ "ក្រុមប្រឹក្សា" អោយមានការប្រុងប្រយ័ត្ន លើរាល់គ្រប់បញ្ហាដែលអាចមានចរិតទាក់ទងនឹងមុខងាររបស់ "ក្រុមប្រឹក្សា" នោះ

ឃ) "គណៈកម្មការ" ត្រូវមានវិធានការដែលខ្លួនយល់ឃើញថាសមស្រប ទាក់ទងទៅនឹងរាល់គ្រប់បញ្ហាដែល "ក្រុមប្រឹក្សា" ផ្ញើមកអោយគណៈកម្មការ ដោយអនុវត្តកថាខ័ណ្ឌ ១ ខនៃមាត្រា ២២

ង) អនុលោមតាមនីតិវិធីដូចមានចែងនៅក្នុងមាត្រា១២ "គណៈកម្មការ" អាចកែប្រែ តារាងទី១ និង តារាងទី២ បាន

ច) "គណៈកម្មការ" អាចទាញអារម្មណ៍រដ្ឋដែលមិនមែនជាភាគីអោយមានការប្រុងប្រយ័ត្នចំពោះសេចក្តីសំរេចនិងអនុសាសន៍ផ្សេងៗ ដែល"គណៈកម្មការ" បានអនុម័តតាមន័យនៃអនុសញ្ញានេះដើម្បីឱ្យរដ្ឋដែលមិនមែនជាភាគីទាំងនោះ ពិនិត្យចាត់វិធានការអោយបានសមស្រប ។

## មាត្រា២២ : មុខងាររបស់ ក្រុមប្រឹក្សា

១. ដោយគ្មានលំអៀងដល់មុខងារផ្សេងៗរបស់គណៈកម្មការនោះទេ តាមន័យនៃមាត្រា ២១ ហើយគ្មានលំអៀងដល់មុខងារផ្សេងៗរបស់ "ក្រុមប្រឹក្សា" និង របស់"គណៈកម្មការ" ទេ តាមន័យនៃអនុសញ្ញាឆ្នាំ១៩៦១ អនុសញ្ញាឆ្នាំ១៩៦១ ដែលបានកែប្រែ និងអនុសញ្ញាឆ្នាំ ១៩៧១ :

ក) ក្រោយពីពិនិត្យលើពត៌មានដែល "ក្រុមប្រឹក្សា" "អគ្គលេខាធិការ" រឺ "គណៈកម្មការ" មាន រឺក្រោយពីពិនិត្យលើពត៌មាន ដែលបានមកពីអង្គការផ្សេងៗរបស់អង្គការសហប្រជាជាតិបើប្រសិនជា "ក្រុមប្រឹក្សា" មានហេតុផលជឿថាខ្លួនមិនបានឆ្លើយតបនឹងគោលបំណងរបស់អនុសញ្ញានេះទេក្នុងវិស័យទាក់ទងនឹងសមត្ថកិច្ចរបស់ខ្លួននោះ "ក្រុមប្រឹក្សា" អាចសុំអោយភាគីមួយរឺភាគីច្រើនជួយផ្តល់ពត៌មានសមហេតុផលទាំងអស់មកខ្លួនបាន ;

ខ) ទាក់ទងនឹងមាត្រា១២ មាត្រា១៣ និង មាត្រា១៦ :

i) ក្រោយពីធ្វើសកម្មភាពស្របតាមវគ្គ (ក) នៃកថាខ័ណ្ឌនេះដោយសារហេតុផលស្ថានភាពបើយល់ឃើញថាចាំបាច់ "ក្រុមប្រឹក្សា" អាចទាមទារសុំអោយភាគីសាមីមានវិធានការការកែតំរូវដែលហាក់ចាំបាច់ក្នុងការធានារ៉ាប់រងអោយអនុវត្តបទបញ្ញត្តិនៃមាត្រា១២ មាត្រា ១៣ និង មាត្រា១៦

ii) មុននឹងធ្វើសកម្មភាពស្របតាមវគ្គ iii ខាងក្រោម "អង្គការ" ត្រូវចាត់ទុកដំណឹងពត៌មានផ្សេងៗដែល "ក្រុមប្រឹក្សា" ផ្លាស់ប្តូរជាមួយនឹងភាគីសាមី ថាជាការសំងាត់ តាមន័យនៃវគ្គដែលមានពីមុននេះ

iii) បើប្រសិនជា "ក្រុមប្រឹក្សា" សំគាល់ឃើញថា ភាគីសាមីមិនបានចាត់វិធានការកែតំរូវតាមការស្នើសុំស្របតាមវគ្គនេះទេនោះ "ក្រុមប្រឹក្សា" អាចទាញអារម្មណ៍របស់ភាគីរបស់ "ក្រុមប្រឹក្សា" និងរបស់ "គណៈកម្មការ" អោយមានការប្រុងប្រយ័ត្នពីបញ្ហានោះ។ គ្រប់របាយការណ៍ទាំងអស់ ដែលបាន បោះផ្សាយតាមន័យនៃវគ្គនេះ ត្រូវតែមានដាក់យោបល់របស់ភាគីសាមីដែរ បើប្រសិនជា ភាគីសាមីនោះស្នើសុំ ។

២. ភាគីនីមួយៗ ត្រូវបានអញ្ជើញទៅជាតំណាងក្នុងសម័យប្រជុំផ្សេងៗរបស់ "ក្រុមប្រឹក្សា" ដែលក្នុងសម័យប្រជុំទាំងនោះបញ្ហា ដែលទាក់ទងនឹងផលប្រយោជន៍ផ្ទាល់របស់ភាគីនីមួយៗ ត្រូវបានលើកយកមកពិនិត្យ ដោយសារអនុវត្តមាត្រានេះ ។

៣. នៅក្នុងករណីដែលសេចក្តីសំរេចរបស់ "ក្រុមប្រឹក្សា" អនុម័តតាមន័យនៃមាត្រានេះពុំមានសំលេងឯកច្ឆន្ទទេ នោះមតិភាគតិចត្រូវតែលាតត្រដាងបង្ហាញប្រាប់ ។

៤. សេចក្តីសំរេចផ្សេងៗរបស់ "ក្រុមប្រឹក្សា" ក្នុងនាមមាត្រានេះ ត្រូវតែអនុម័តដោយសំលេងភាគច្រើន ២ភាគ៣ នៃចំនួនសរុបសមាជិកទាំងអស់របស់ "ក្រុមប្រឹក្សា" ។

៥. ក្នុងការអនុវត្តមុខងារដែលមានចំពោះខ្លួនតាមន័យនៃវគ្គ (ក) កថាខ័ណ្ឌ១ នៃមាត្រានេះ "ក្រុមប្រឹក្សា" ត្រូវធានាពីចរិតអាថិកំបាំងគ្រប់ពត៌មានទាំងអស់ ដែលខ្លួននឹងមាន ។

៦. ការប្រតិបត្តិសន្ធិសញ្ញា រឺ កិច្ចព្រមព្រៀង ដែលបានធ្វើអោយមានរវាងភាគីផ្សេងៗ ដោយអនុលោមតាម បទបញ្ញត្តិនៃអនុសញ្ញានេះមិនទាក់ទងនឹងការទទួលខុសត្រូវដែល "ក្រុមប្រឹក្សា" មានទេ តាមន័យនៃមាត្រា នេះ ។

៧. បទបញ្ញត្តិនៃមាត្រានេះ មិនអាចយកមកអនុវត្ត ជាមួយនឹងជំលោះរវាងភាគីដែលពាក់ព័ន្ធនឹងបទបញ្ញត្តិនៃមាត្រា៣២បានទេ ។

## មាត្រា២៣ : របាយការណ៍របស់ក្រុមប្រឹក្សា

១. "ក្រុមប្រឹក្សា" ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ពីសកម្មភាពរបស់ខ្លួន ក្នុងនោះ "ក្រុមប្រឹក្សា" ត្រូវធ្វើវិភាគ អំពីពត៌មានដែលខ្លួនមាន ដោយរាយការណ៍ក្នុងករណីសមស្រប ពីការពន្យល់ផ្សេងៗជាយថាហេតុដែលភាគីនានាបានផ្តល់មកអោយរឺការពន្យល់ដែលខ្លួនទាមទារបានមកពីភាគីទាំងនោះព្រមទាំងលើកពីការសង្កេត និងអនុសាសន៍ដែល "ក្រុមប្រឹក្សា" ចង់សំណូមពរអោយធ្វើ ។ "ក្រុមប្រឹក្សា" អាចរៀបចំរបាយការណ៍បន្ថែមផ្សេងៗទៀត បើប្រសិនជា "ក្រុមប្រឹក្សា" យល់ឃើញថាចាំបាច់ ។ របាយការណ៍ត្រូវបង្ហាញជូន "ក្រុមប្រឹក្សា" តាមរយៈ "គណៈកម្មការ" ដែល "គណៈកម្មការ" នោះ អាចលើកពីការសង្កេតដែលខ្លួនយល់ឃើញ ថាគួរដល់កាលពេលវេលានោះ ។

២. របាយការណ៍របស់ "ក្រុមប្រឹក្សា" ត្រូវជូនដំណឹងទៅភាគី និងត្រូវបោះពុម្ពផ្សាយជាក្រោយដោយអគ្គលេខាធិការ ។ ភាគីទាំងឡាយត្រូវអនុញ្ញាតអោយមានការចែកចាយរបស់ខ្លួនគ្មានកំណត់ ។

**មាត្រា២៤ : ការអនុវត្តនូវវិធានការដែលតឹងរឹងជាងវិធានការដែលតម្រូវអោយមានដោយអនុសញ្ញានេះ**

ភាគីអាចអនុម័តយកវិធានការតឹងរឹង រឺធ្ងន់ធ្ងរខ្លាំងជាង វិធានការដែលគ្រោងទុកក្នុងអនុញ្ញានេះ បើប្រសិនជាភាគីយល់ឃើញថាចង់ធ្វើ រឺចាំបាច់ សំរាប់បង្ការការពារ រឺលុបបំបាត់ការចរាចរខុសច្បាប់ ។

**មាត្រា២៥ : គ្មានបដិបញ្ញត្តិដល់សិទ្ធិ និងកាតព្វកិច្ចដែលមានមកពីសន្ធិសញ្ញាពីមុនៗមករន**

បទបញ្ញត្តិទាំងឡាយ នៃអនុសញ្ញានេះមិនបដិបញ្ញត្តិដល់សិទ្ធិ រឺកាតព្វកិច្ចណាមួយដែលអនុសញ្ញាឆ្នាំ១៩៦១

អនុសញ្ញាឆ្នាំ ១៩៦១ ដែលបានកែប្រែ រឺ អនុសញ្ញាឆ្នាំ១៩៧១ បានទទួលស្គាល់ រឺ តំរូវលើភាគីរបស់អនុសញ្ញានេះ នោះទេ ។

**មាត្រា២៦ : ហត្ថលេខា**

អនុសញ្ញានេះបើកចំហ អោយចុះហត្ថលេខា នៅការិយាល័យសហប្រជាជាតិ នាទីក្រុងវីយែន ចាប់ពីថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៨៨ ដល់ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ១៩៨៩ ហើយបន្ទាប់មកទៀត នៅទីស្នាក់ការនៃអង្គការសហប្រជាជាតិ នាទីក្រុងញូវយ៉ក រហូតដល់ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៨៩ :

ក) ចំពោះគ្រប់រដ្ឋទាំងអស់

ខ) ចំពោះណាមីប៊ី ដែលមានក្រុមប្រឹក្សាសហប្រជាជាតិ សំរាប់ណាមីប៊ីជាតំណាង

គ) ចំពោះបណ្តាអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលមានសមត្ថកិច្ចរឿងចរចាក្នុងរឿងធ្វើអោយមានកិច្ចព្រមព្រៀង និង រឿងអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិទាក់ទងនឹងបញ្ហាផ្សេងៗ ដែលមានចែងនៅក្នុងកម្មវត្ថុរបស់អនុសញ្ញា សេចក្តីយោងផ្សេងៗដែលមានក្នុងអនុសញ្ញាសំរាប់អោយអង្គភាពរបស់ភាគីរដ្ឋ រឺ អង្គភាពជាតិ អាចអនុវត្តចំពោះអង្គការទាំងនោះបានក្នុងកំរិតព្រំដែនសមត្ថកិច្ចរបស់អង្គការទាំងនោះ ប៉ុណ្ណោះ ។

**មាត្រា២៧ : ការអោយសច្ចាប័ន សូ្វការ ការយល់ព្រម ឬ លិខិតបញ្ជាក់ផ្លូវការ**

១. អនុសញ្ញានេះត្រូវធ្វើសច្ចាប័នមានសូ្វការ រឺ មានការយល់ព្រមពីរដ្ឋទាំងឡាយ និង ពីណាមីប៊ី ដែលមានក្រុមប្រឹក្សាសហប្រជាជាតិសំរាប់ណាមីប៊ីជាតំណាង និង ត្រូវមានលិខិតបញ្ជាក់ផ្លូវការពីអង្គការសមា-

ហរិណកម្មសេដ្ឋកិច្ចតំបន់ ដូចមានចែងក្នុងវគ្គ(គ) នៃមាត្រា២៦ ។ ឧបករណ៍សច្ចាប័ន ស្ទីការ រឺការយល់ព្រមនិងឧបករណ៍ដែលទាក់ទងនឹងលិខិតបញ្ជាក់ផ្លូវការត្រូវយកមកតំកល់ទុកនៅអមអគ្គលេខាធិការ ។

២. នៅក្នុងឧបករណ៍បញ្ជាក់ផ្លូវការរបស់ខ្លួនអង្គការសមាហរិណកម្មសេដ្ឋកិច្ចតំបន់ នឹងបញ្ជាក់ច្បាស់លាស់ពី វិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន ក្នុងវិស័យដែលទាក់ទងនឹងអនុសញ្ញានេះ ។ ម្យ៉ាងទៀត អង្គការទាំងនោះនឹងផ្តល់ពតិមានជូនអគ្គលេខាធិការនូវរាល់ការកែប្រែ ដែលមានក្នុងវិសាលភាពនៃសមត្ថកិចរបស់ខ្លួនក្នុងវិស័យផ្សេងៗ ទាក់ទងនឹងអនុសញ្ញា ។

## មាត្រា២៨ : ការសុំចុះជាសមាជិក

១. អនុសញ្ញានេះនៅតែបើកចំហ អោយសុំចុះជាសមាជិក ចំពោះគ្រប់រដ្ឋ ចំពោះណាមីប៊ី ដែលមានក្រុមប្រឹក្សាសហប្រជាជាតិសំរាប់ណាមីប៊ីជាតំណាង និង ចំពោះបណ្តាអង្គការសមាហរិណកម្មសេដ្ឋកិច្ចតំបន់ដូចមានចែងក្នុងវគ្គ (គ) នៃមាត្រា២៦ ។ ការសុំចុះជាសមាជិកនឹងត្រូវធ្វើ ដោយមានដាក់តំកល់ទុកឧបករណ៍សុំចុះជាសមាជិក អមអគ្គលេខាធិការ ។

២. នៅក្នុងឧបករណ៍សុំចុះជាសមាជិករបស់ខ្លួន បណ្តាអង្គការសមាហរិណកម្មសេដ្ឋកិច្ចតំបន់ត្រូវបញ្ជាក់ច្បាស់លាស់ពីវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន នៅក្នុងវិស័យទាំងឡាយដែលទាក់ទងនឹងអនុសញ្ញានេះ។ ម្យ៉ាងទៀតអង្គការទាំងនោះនឹងជូនពតិមានទៅអគ្គលេខាធិការគ្រប់ការកែប្រែទាំងអស់ដែលមានចំពោះវិសាលភាព នៃសមត្ថកិច្ចរបស់ខ្លួន នៅក្នុងវិស័យទាំងឡាយណាដែលពាក់ព័ន្ធនឹងអនុសញ្ញា ។

## មាត្រា ២៩ : ការចូលជាធរមាន

១. អនុសញ្ញានេះ ត្រូវចូលជាធរមាន នាថ្ងៃទីកៅសិប បន្ទាប់ពីថ្ងៃតំកល់ទុកអមអគ្គលេខាធិការ នូវឧបករណ៍ទីម្ភៃ នៃការអោយសច្ចាប័ន ស្ទីការ និងការយល់ព្រម រឺ ការសុំចុះជាសមាជិកពីសំណាក់ រដ្ឋនានា រឺ ពីសំណាក់ណាមីប៊ី ដែលតំណាងដោយក្រុមប្រឹក្សាសំរាប់ណាមីប៊ី ។

២. ចំពោះរដ្ឋនីមួយៗ រឺ ចំពោះណាមីប៊ីដែលមានក្រុមប្រឹក្សាសំរាប់ណាមីប៊ីជាតំណាង ដែលនឹង ផ្តល់សច្ចាប័ន នឹងធ្វើស្ទីការ រឺ នឹងយល់ព្រមលើអនុសញ្ញានេះ រឺ និង សុំចុះជាសមាជិកនៃអនុសញ្ញានេះនៅក្រោយការតំកល់ទុកទីម្ភៃនូវឧបករណ៍សច្ចាប័ន ស្ទីការ ការយល់ព្រម រឺការសុំចុះជាសមាជិក នោះអនុសញ្ញា នឹងចូលជាធរមាននៅថ្ងៃទីកៅសិប បន្ទាប់ពីថ្ងៃតំកល់ទុកឧបករណ៍សច្ចាប័ន ស្ទីការ ការយល់ព្រម រឺ ការសុំចុះជាសមាជិករបស់ខ្លួនរួចមក ។

៣. ចំពោះអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់នីមួយៗ ដូចមានចែងក្នុងវគ្គ (គ) នៃមាត្រា ២៦ ដែលនឹងតំកល់ទុកឧបករណ៍មួយទាក់ទង នឹង លិខិតបញ្ជាក់ផ្លូវការ រឺ ឧបករណ៍សុំចុះជាសមាជិក អនុសញ្ញានេះ នឹងចូលជាធរមាន នៅកាលបរិច្ឆេទណាមួយដែលវែងជាងគេ ក្នុងចំណោមកាលបរិច្ឆេទពីរ ដូចតទៅ : ថ្ងៃទីកៅសិបក្រោយពីការដំកល់ទុកឧបករណ៍ដូចបានពោលមកនោះ រឺ កាលបរិច្ឆេទដែល អនុសញ្ញានឹងចូលជាធរមាន ដោយអនុលោមតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ។

## មាត្រា ៣០ : ការបដិសេធ

១. រាល់ភាគី អាចបដិសេធអនុសញ្ញានេះបានគ្រប់ពេលវេលាទាំងអស់ តាមរយៈលិខិតជូនដំណឹងដែល សរសេរជំរាបជូនទៅអគ្គលេខាធិការ ។

២. ការបដិសេធនឹងចាប់អនុវត្តបានសំរាប់ភាគីសាមីមួយឆ្នាំ ក្រោយពីកាលបរិច្ឆេទដែលអគ្គលេខាធិ-ការទទួលលិខិតជូនដំណឹងនេះ ។

## មាត្រា ៣១ : វិសោធនកម្ម

១. រាល់ភាគីអាចលើកសំណើសុំធ្វើវិសោធនកម្មអនុសញ្ញានេះបាន ។ អត្ថបទវិសោធនកម្ម ដូចបាន ពោលមកនោះ ព្រមទាំងមតិយោបល់ ដែលជាហេតុផលសុំធ្វើវិសោធនកម្មនោះភាគីនោះ ត្រូវជូនពតិមាន ទៅអគ្គលេខាធិការហើយអគ្គលេខាធិការបញ្ជូនបន្តអត្ថបទ និង មតិយោបល់ទាំងនោះ ទៅអោយភាគីដទៃ ទៀតហើយស្នើសុំពីភាគីទាំងនោះមកវិញបើប្រសិនជាភាគីទាំងនោះយល់ព្រមទទួលយកវិសោធនកម្ម ដែល ស្នើនោះ ។ បើប្រសិនជា អត្ថបទវិសោធនកម្ម ដូចបានចែកជូនទៅនោះ គ្មានភាគីណាមួយច្រានចោលក្នុង រយៈពេល ២៤ ខែ បន្ទាប់ពីការជូនដំណឹងរបស់ខ្លួន វិសោធនកម្មដូចបានពោលនោះត្រូវទុកជាសុខចិត្តព្រម ទទួលយក ហើយត្រូវចូលជាធរមានសំរាប់ភាគីនីមួយៗកៅសិបថ្ងៃក្រោយពីភាគីនោះបានតំកល់ទុកនៅ អមអគ្គលេខាធិការនូវឧបករណ៍បញ្ជាក់ពីការយល់ព្រម ដែលមានទាក់ទងនឹងវិសោធនកម្មនោះ ។

២. បើប្រសិនជាវិសោធនកម្មត្រូវបានច្រានចោលពីភាគីមួយ អគ្គលេខាធិការត្រូវធ្វើការពិគ្រោះជា មួយនឹងភាគីផ្សេងៗ ហើយបើប្រសិនជាមានភាគច្រើនទាមទារអគ្គលេខាធិការ លើកយកបញ្ហាព្រមទាំង ការសង្កេតទាំងអស់ដែលភាគីផ្សេងៗលើកយកមកបង្ហាញនៅចំពោះមុខក្រុមប្រឹក្សា ហើយក្រុមប្រឹក្សាអាច សំរេចកោះប្រជុំសន្និសីទមួយដោយអនុលោមតាមកថាខ័ណ្ឌ ៤ នៃមាត្រា ៦២ របស់ធម្មនុញ្ញសហ ប្រជាជាតិ ។ រាល់វិសោធនកម្ម ដែលបានមកពីសន្និសីទប្រភេទនេះ ត្រូវបានកត់ត្រាទុកក្នុងពិធីសារ

វិសោធនកម្មមួយ ។ ភាគីទាំងឡាយដែលយល់ព្រមភ្ជាប់ខ្លួនទៅនឹងពិធីសារនេះ ត្រូវជូនពត៌មានអោយបានច្បាស់លាស់ទៅអគ្គលេខាធិការ ។

**មាត្រា៣២ : ការដោះស្រាយអធិករណ៍**

១. បើប្រសិនជា អធិករណ៍កើតមានរវាងភាគីពីរ រឺភាគីច្រើន ទាក់ទងនឹងការបកស្រាយ រឺ ការអនុវត្តអនុសញ្ញានេះភាគីត្រូវពិគ្រោះគ្នាក្នុងចេតនាដោះស្រាយអធិករណ៍នេះ តាមមធ្យោបាយនៃការចរចា ការស៊ើបអង្កេត ការសំរុះសំរួល ការផ្សះផ្សា ការសំរេចរបស់អាជ្ញាកណ្តាល រឺ ឧបាស្រ័យទៅអង្គការតំបន់ផ្សេងៗ រឺក៏ដោះស្រាយអធិករណ៍នេះតាមមធ្យោបាយតុលាការ រឺ តាមមធ្យោបាយសន្តិភាពផ្សេង ទៀតដែលភាគី ទាំងនោះជ្រើសរើស ។

២. ចំពោះជំលោះបែបណាមួយ ដែលមិនអាចដោះស្រាយបាន តាមមធ្យោបាយដូចបានគ្រោងទុកក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ត្រូវដាក់ជូនទៅតុលាការអន្តរជាតិ ដើម្បីធ្វើការវិនិច្ឆ័យសំរេចតាមសំណើរបស់ រដ្ឋភាគីណាមួយនៃជំលោក ។

៣. បើប្រសិនជាអង្គការសមាហរ័ណកម្មសេដ្ឋកិច្ចតំបន់ ដូចបានសំដៅយកក្នុងវគ្គ (គ) នៃមាត្រា ២៦ ជាភាគីក្នុងអធិករណ៍ដែលមិនអាចដោះស្រាយបានតាមរបៀបដូចមានគ្រោងទុកក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ អង្គការសមាហរ័ណកម្មសេដ្ឋកិច្ចតំបន់តាមរយៈរដ្ឋសមាជិកនៃអង្គការសហប្រជាជាតិអាចសុំអោយក្រុមប្រឹក្សាទាមទារសុំយោបល់ពិគ្រោះពី "តុលាការ" អន្តរជាតិ យោបល់នេះនឹងត្រូវចាត់ទុកថាជាយោបល់ដាច់ស្រេច តាមន័យនៃមាត្រា ៦៥ នៃ "លក្ខន្តិកៈ" របស់ "តុលាការ" ។

៤. នៅពេល ចុះហត្ថលេខា រដ្ឋនីមួយៗដែលអោយសច្ចាប័ន ធ្វើស៊ូការ រឺយល់ព្រមចំពោះ អនុសញ្ញានេះ រឺ ដែលចុះជាសមាជិកនៃអនុសញ្ញានេះរឺមួយគ្រប់អង្គការសមាហរ័ណកម្មសេដ្ឋកិច្ចតំបន់នីមួយៗនៅពេលចុះហត្ថលេខា បានដកល់ទុកលិខិតយល់ព្រមផ្លូវការ រឺ លិខិតចុះជាសមាជិក អាចប្រកាសសុំខ្លួនមិនពាក់ព័ន្ធ នឹងបទបញ្ញត្តិ នៃកថាខ័ណ្ឌ ២ និង កថាខ័ណ្ឌ ៣ នៃមាត្រានេះបាន ។ ភាគីដទៃទៀតមិនពាក់ព័ន្ធនឹងបទ បញ្ញត្តិ នៃកថាខ័ណ្ឌ ២ និង ៣ នេះ ជាមួយនឹង ភាគីមួយដែលបានប្រកាសបែបនេះទេ ។

៥. គ្រប់ភាគីដែលបានធ្វើសេចក្តីប្រកាស តាមន័យនៃកថាខ័ណ្ឌ ៤ មាត្រានេះ អាចដកយកសេចក្តីប្រកាស នេះមកវិញបាន គ្រប់ពេលវេលា ដោយធ្វើលិខិតជូនដំណឹង ជំរាបជូនទៅអគ្គលេខាធិការ ។

**មាត្រា៣៣ : អត្ថបទយថាភូត**

អត្ថបទជាភាសាអង់គ្លេស អារ៉ាប់ ចិន អេស្ប៉ាញ៉ុល បារាំង និង រុស្ស៊ី នៃអនុសញ្ញានេះ ជាបន្ទាល់ស្មើគ្នា ។

**មាត្រា៣៤ : អ្នកទទួលរក្សាទុក**

អគ្គលេខាធិការគឺអ្នកទទួលរក្សាទុកអនុសញ្ញានេះ ។

ជាសក្ខីភាព ហត្ថលេខីទាំងឡាយដែលបានទទួលការអនុញ្ញាតត្រឹមត្រូវបានចុះហត្ថលេខាលើអនុសញ្ញានេះ។

ធ្វើនៅទីក្រុងវីយែន ជាមួយច្បាប់ដើម នៅថ្ងៃទីម្ភៃ ខែធ្នូ ឆ្នាំមួយពាន់ប្រាំបួនរយប៉ែតសិបប្រាំបី ។

## ឧបសម្ព័ន្ធនៃអនុសញ្ញាឆ្នាំ ១៩៨៨

### ឧបសម្ព័ន្ធ

តារាងពិនិត្យឡើងវិញមានបញ្ចូលវិសោធនកម្មទាំងឡាយ ដែលគណៈកម្មការគ្រឿងញៀនបានធ្វើ ចូលជាធមានចាប់ពីថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ១៩៩២

| តារាងទី ១ | តារាង ទី២ |
|---|---|
| អាស៊ីដ អិន អាសេទីឡង់ត្រានីលីក Acide N-acétylanthranilique | អាសេតូន Acétone |
| អាស៊ីដ លីហ្សេរហ្ស៊ីក Acide lysergique | អាស៊ីដ អង់ត្រានីលីក Acide anthranilique |
| អេហ្វេទ្រីន Ephédrine | អាស៊ីដ ក្លរីឌ្រីក Acide chlorhydrique |
| អែរហ្គូមេទ្រីន Ergométrine | អាស៊ីដ ហ្វេនីឡាអាសេទិក Acide phénylacétique |
| អែរហ្គូតាមីន Ergotamine | អាស៊ីដ ស៊ុលផួរិក Acide sulfurique |
| អ៊ីសូសាហ្វ្រូល Isosafrole | អានីឌ្រីដ អាសេទិក Anhydride acétique |

មេទីឡែនឌីអុកស៊ី-៣.៤ ហ្វេនីល ប្រូប៉ាណូន២ - Méthy-lènedioxy-3,4 phényl propanone-2

ហ្វេនីល-១ ប្រូប៉ាណូន - ២ phényl-1 propanone-2

ពីពេរ៉ូណាល់ Pipéronal

ប្ស៊ីដូអេហ្វេទ្រីន Pseudoéphédrine

សាហ្វ្រូល Safrole

អំបិលនៃសារធាតុ ដូចមានចុះក្នុងបញ្ជីតារាងនេះ នៅគ្រប់ករណីទាំងអស់ លទ្ធភាពអត្ថិភាពអំបិលទាំងនេះអាចមាន.

អេទែរ អេទីលីក Ether éthylique

មេទីលេទីលសេតូន Méthyléthylcétone

ពែម៉ង់កាណាត ដឺ ប៉ូតាស្យូម Permanganate de potassium

ពិពេរីឌីន Pipéridine

តូលុយអែន Toluène

អំបិលនៃសារធាតុដូចមានចុះក្នុងបញ្ជីតារាងនេះនៅគ្រប់ករណីទាំងអស់ លទ្ធភាពអត្ថិភាពអំបិលទាំងនេះអាចមាន (អំបិលនៃអាស៊ីតគ្លរីទ្រិក និង នៃអាស៊ីដស៊ុលផួរិកដាច់ខាតមិនរាប់បញ្ចូលទេ)